ព្រឹទ្ធសភា



នីតិកាលទី៣

(២០១២-២០១៨)

ព្រឹទ្ធសភានីតិកាលទី៣

នៃ

ព្រះរាជាណាចក្រកម្ពុជា



សម័យប្រជុំដំបូងព្រឹទ្ធសភានីតិកាលទី៣
ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២
ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត
របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា



រូបថតអនុស្សាវរីយ៍នាសម័យប្រជុំដំបូងនៃព្រឹទ្ធសភា នីតិកាលទី៣

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អារម្ភកថា

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំកសាងសៀវភៅស្តីពី "**ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៣ (២០១២-២០១៨)**" ទាក់ទងទៅនឹង តួនាទី ភារកិច្ច សមត្ថកិច្ចនៃព្រឹទ្ធសភា ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា នីតិវិធីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ បញ្ជីរាយនាមគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានានៃព្រឹទ្ធសភា និងបញ្ជីរាយនាមសមាជិកា សមាជិកព្រឹទ្ធសភាតាមលំដាប់អក្សរ តាមលំដាប់អាយុ ក្រុមមិត្តភាពរវាងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាសភាប្រទេសជាមិត្ត ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុក IPU, AIPA, APF, CLV ក្រុមសមាជិកាព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ បញ្ជីរាយនាមសមាជិកព្រឹទ្ធសភាតាមគណបក្សនយោបាយ ដែលមានអាសនៈនៅព្រឹទ្ធសភានីតិកាលទី៣ ។

សៀវភៅស្តីពី "**ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៣ (២០១២-២០១៨)**" ត្រូវបានប្រមូលផ្តុំចងក្រងឡើងទៅតាមព័ត៌មានដែលសមាជិកា សមាជិកព្រឹទ្ធសភាផ្តល់ឲ្យ ព្រមទាំងឯកសារជាមូលដ្ឋានផ្សេងៗទៀតរបស់ព្រឹទ្ធសភា ។

ព្រឹទ្ធសភានីតិកាលទី៣ បានបើកសម័យប្រជុំដំបូងនៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ។ ទន្ទឹមនឹងបទពិសោធន៍ការងារ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានសម្រាប់បម្រើឲ្យកិច្ចដំណើរការ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភាដែលមានកន្លងមក ក្នុងនីតិកាលទី៣នេះ ព្រឹទ្ធសភាកសាងបាននូវបទបញ្ជាផ្ទៃក្នុងថ្មី ដែលកំណត់អំពីនីតិវិធីការងារស្របទៅតាមស្តង់ដារនៃសភាប្រជាធិបតេយ្យ ។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សូមសង្ឃឹមជឿជាក់ថា សៀវភៅស្តីពី "**ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៣ (២០១២-២០១៨)**" នឹងផ្តល់នូវសារៈសំខាន់ជួយសម្រួលដល់ដំណើរការប្រតិបត្តិការងាររបស់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រួមទាំងសាធារណជនទូទៅក្នុងការស្វែងយល់អំពីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៦
អគ្គលេខាធិការ

អ៊ុំ សារឹទ្ធ

មាតិកា

រូបថតសម័យប្រជុំដំបូងនីតិកាលទី៣ និងរូបថតអនុស្សាវរីយ៍

អារម្ភកថា

ទំព័រ

ប្រវត្តិព្រឹទ្ធសភា ១

១. ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា ២

  ១.១. ការរៀបចំព្រឹទ្ធសភា ២

  ១.២. ការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា ៣

២. តួនាទី និងនាវកិច្ចរបស់ព្រឹទ្ធសភា ៣

៣. ភាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា ៤

៤. នីតិវិធីពិនិត្យ និងឲ្យឃោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ៨

៥. គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ១០

៦. បញ្ជីរាយនាមសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)

  (តាមលំដាប់អក្ខរក្រមខ្មែរ) ១១

៧. បញ្ជីរាយនាមសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)

  (តាមលំដាប់អាយុ) ១៣

៨. បញ្ជីរាយនាមសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)

  (តាមមណ្ឌលតូមិនាគ) ១៥

៩. បញ្ជីរាយនាមសមាជិកព្រឹទ្ធសភានីតិកាលទី៣ តាមគណបក្ស ១៨

១០. តារាងប្រៀបធៀបចំនួនសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)

  តាមប្រតិភគណបក្ស និងស្ថាប័ន ២១

១១. តារាងប្រៀបធៀបចំនួនសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)

  តាមភេទ ២១

១២. តារាងប្រៀបធៀបចំនួនសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)

  តាមលំដាប់អាយុ ២២

១៣. សមាសនាពគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសនានីតិកាលទី៣ ..... **២៣**

១៤. សមាសនាពថ្នាក់ដឹកនាំ និងសមាសនាពគណៈកម្មការនានា របស់ព្រឹទ្ធសនានីតិកាលទី៣ ..... **២៤**

១៥. សមាជិកព្រឹទ្ធសនាក្រៅគណៈកម្មការ **២៧**

១៦. នារកិច្ចរបស់ថ្នាក់ដឹកនាំព្រឹទ្ធសនានីតិកាលទី៣ (២០១២-២០១៨) **២៨**

១៧. តួនាទី នារកិច្ច និងសមត្ថកិច្ចគណៈកម្មការនានានៃព្រឹទ្ធសនា **៣០**

១. សមាសនាព តួនាទី នារកិច្ច និងសមត្ថកិច្ចគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត និងសមាសនាពលេខាធិការដ្ឋាន **៣០**

២. សមាសនាព តួនាទី នារកិច្ច និងសមត្ថកិច្ចគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម និងសមាសនាពលេខាធិការដ្ឋាន **៣៤**

៣. សមាសនាព តួនាទី នារកិច្ច និងសមត្ថកិច្ចគណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧត្តុនិយម អតីវឌ្ឍន៍ជនបទ និងបរិស្ថាន និងសមាសនាពលេខាធិការដ្ឋាន **៣៧**

៤. សមាសនាព តួនាទី នារកិច្ច និងសមត្ថកិច្ចគណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសនា ព្រឹទ្ធសនា អធិការកិច្ច និងមុខងារសាធារណៈ និងសមាសនាពលេខាធិការដ្ឋាន **៤១**

៥. សមាសនាព តួនាទី នារកិច្ច និងសមត្ថកិច្ចគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន និងសមាសនាពលេខាធិការដ្ឋាន **៤៤**

៦. សមាសនាព តួនាទី នារកិច្ច និងសមត្ថកិច្ចគណៈកម្មការនីតិកម្ម និងយុត្តិធម៌ និងសមាសនាពលេខាធិការដ្ឋាន **៤៧**

៧. សមាសនាព តួនាទី នារកិច្ច និងសមត្ថកិច្ចគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ និងសមាសនាពលេខាធិការដ្ឋាន **៥០**

៨. សមាសនាព តួនាទី នារកិច្ច និងសមត្ថកិច្ចគណៈកម្មការសុខាតិច្ចាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី និងសមាសនាពលេខាធិការដ្ឋាន **៥៣**

៩. សមាសនាព តួនាទី នារកិច្ច និងសមត្ថកិច្ចគណៈកម្មការ សាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសមាសនាពលេខាធិការដ្ឋាន **៥៦**

១០. សមាសនាព តួនាទី នារកិច្ច និងសមត្ថកិច្ចគណៈកម្មការអង្កេត ឃោសសម្អាត និងប្រឆាំងអំពើពុករលួយ និងសមាសនាពលេខាធិការដ្ឋាន **៦០**

១៨. សមាសភាព តួនាទី ភារកិច្ច និងសមត្ថកិច្ចក្រុមសមាជិកព្រឹទ្ធសភានីតិកាលទី៣ ..... ៦៣
១៩. សមាសភាព តួនាទី ភារកិច្ច និងសមត្ថកិច្ចក្រុមការងារអន្តរជាតិព្រឹទ្ធសភា និងក្រុមមិត្តភាពជាមួយសភាប្រទេសនានា ៦៨
ក. ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចការអន្តរសភាអាស៊ាន (AIPA) ៦៨
ខ. ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចការ សហភាពអន្តរសភា (IPU) ៧១
គ. ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចការ សភានីយោយភាសាបារាំង (APF) ៧៤
ឃ. ក្រុមការងារសហប្រតិបត្តិការព្រឹទ្ធសភាកម្ពុជា-សភាបណ្តាប្រទេស ៧៧
ង. តួនាទី ភារកិច្ច និងសមត្ថកិច្ចក្រុមទទួលបន្ទុកកិច្ចការអន្តរជាតិព្រឹទ្ធសភា ៧៩
ច. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាសាធារណរដ្ឋសង្គមនិយមវៀតណាម (VIETNAM) ៨១
ឆ. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (LAOS) ៨៣
ជ. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាក្រុមប្រឹក្សានយោបាយប្រជាជនចិន (CHINA) ៨៥
ឈ. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភារាជាណាចក្រជប៉ុន (JAPAN) ៨៧
ញ. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង (FRANCE) ៨៩
ដ. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាព្រះរាជាណាចក្រថៃឡង់ដ៍ (THAILAND) ៩១
ឋ. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាជាមួយ សភាអូស្ត្រាលី និងញូហ្សីឡែន (AUSTRALIA & NEW ZELAND) ៩៣
ឌ. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាសហព័ន្ធវ៉ាឡូនី-ប្រ៊ុចសែល (Federation Wallonie-Bruxelles) ៩៥
ឍ. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាទួរគី (TURKEY) ៩៧
ណ. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាសហព័ន្ធមីយ៉ាន់ម៉ា (Myanmar) ៩៩

ត. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
ជាមួយសភាម៉ុងហ្គោលី (**Mongolia**) ១០១
ថ. ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
ជាមួយក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធ នៃសហព័ន្ធរុស្សី (**Russia**) ១០៣
ទ. តួនាទី ភារកិច្ច និងសមត្ថកិច្ចក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា
នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាជាមិត្ត ១០៥
ធ. ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចការអន្តរសភាកម្ពុជា-ឡាវ-វៀតណាម
ដើម្បីជម្រុញ និងតាមដានការអនុវត្តន៍នូវនយោបាយអភិវឌ្ឍត្រីកោណ ១០៧
ន. ការរៀបចំក្រុមសមាជិកព្រឹទ្ធសភាប្រចាំតូមិនាគ ១០៩
ប. តួនាទី ភារកិច្ច និងសមត្ថកិច្ចក្រុមសមាជិកព្រឹទ្ធសភាប្រចាំតូមិនាគ ១១០
ផ. សមាសភាពក្រុមសមាជិកព្រឹទ្ធសភាប្រចាំតូមិនាគ សម្រាប់នីតិកាលទី៣ ..... ១១១
ព. សមាសភាពលេខាធិការដ្ឋានអមក្រុមសមាជិកព្រឹទ្ធសភាប្រចាំតូមិនាគទាំង៨ ..... ១១៤
ភ. ការរៀបចំក្រុមសមាជិកាព្រឹទ្ធសភា ១១៦
ម. សមាសភាព តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ក្រុមសមាជិកាព្រឹទ្ធសភា ១១៧
យ. សមាសភាពលេខាធិការដ្ឋានអមក្រុមសមាជិកាព្រឹទ្ធសភា ១១៩
រ. សមាសភាពអ្នកនាំពាក្យព្រឹទ្ធសភា ១២០
ល. សមាសភាពលេខាធិការដ្ឋានអ្នកនាំពាក្យស្ថាប័នព្រឹទ្ធសភា ១២០
វ. តួនាទី ភារកិច្ច និងសមាសភាពក្រុមជនបង្គោលប្រឆាំងអំពើពុករលួយព្រឹទ្ធសភា ១២១
ស. តួនាទី ភារកិច្ច និងសមាសភាពលេខាធិការដ្ឋាននៃក្រុមជនបង្គោលប្រឆាំង
អំពើពុករលួយនៃព្រឹទ្ធសភា ១២៣

២០. បញ្ជីរាយនាមសមាជិកព្រឹទ្ធសភា និងស្ថាករថយន្តព្រឹទ្ធសភា ១២៥

២១. បញ្ជីរាយនាម សមាជិកា សមាជិកព្រឹទ្ធសភា និងលេខទូរស័ព្ទ ១២៧

២២. សញ្ញាសក្តិ និងឯកសណ្ឋានរបស់សមាជិកព្រឹទ្ធសភា ១២៩

➢ **ប្រវត្តិរូបសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជានីតិកាលទី៣ (២០១២-២០១៨)** ១៣៥

ប្រវត្តិព្រឹទ្ធសភា

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងបន្ទាប់ពីកិច្ចប្រជុំរវាងថ្នាក់ដឹកនាំជាន់ខ្ពស់ គណបក្សនយោបាយធំៗទាំងពីរ នាថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់អតីតព្រះមហាក្សត្រព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** នៅព្រះបរមរាជវាំង។ កិច្ចប្រជុំដ៏សំខាន់នេះ បានបញ្ចប់វិបត្តិនយោបាយ លើកកម្ពស់ការបង្រួបបង្រួមផ្សះផ្សាជាតិ និងពង្រឹងស្ថេរភាពនយោបាយ ដោយបានឯកភាពគ្នាធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាតាមច្បាប់ធម្មនុញ្ញ ដែលបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ។

ការបង្កើតព្រឹទ្ធសភានេះ គឺជាព្រឹត្តិការណ៍នយោបាយដ៏ចម្បងមួយ ក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលបានបង្ហាញឱ្យឃើញនូវពន្លឺថ្មីមួយសម្រាប់អនាគតនៃប្រទេសកម្ពុជា ព្រមទាំងបង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តជាបន្តបន្ទាប់ ក្នុងការកសាងលទ្ធិប្រជាធិបតេយ្យ និងការពង្រឹងនីតិរដ្ឋ។ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី១ បានបើកសម័យប្រជុំ លើកទី១ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។

ព្រឹទ្ធសភានីតិកាលទី១ (១៩៩៩-២០០៦) កើតឡើងដោយការតែងតាំង មានសមាជិកចំនួន ៦១រូប ក្នុងនេះមានគណបក្សប្រជាជនកម្ពុជា ៣៣រូប ហ៊ុនសុិនប៊ិច ២១រូប និងគណបក្សសមរង្ស៊ី ៧រូប (ការបែងចែកអាសនៈទៅតាមចំនួនកូតានៃគណបក្សមានអាសនៈក្នុងរដ្ឋសភានីតិកាលទី២) សម្រាប់រយៈពេល ៥ឆ្នាំ ។ ព្រឹទ្ធសភានីតិកាលទី១ បានបន្តនីតិកាលរបស់ខ្លួនចំនួន ២ដង (ម្តង១ឆ្នាំ) ៖

- **លើកទី១.** ព្រះរាជសារចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៤ របស់ព្រះមហាក្សត្រ **នរោត្តម សីហមុនី** ព្រឹទ្ធសភាបានបន្តនីតិវិធីបោះឆ្នោតសម្ងាត់ក្នុងសម័យប្រជុំលើកទី៩ នាថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៤ ដោយមានសំឡេងគាំទ្រចំនួន ៤៩សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។ ប្រកាសបន្តនីតិកាលរយៈពេល ០១ឆ្នាំ (គិតចាប់ពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៤ ដល់ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៥) តាមព្រះរាជក្រឹត្យៈ នស/រកត/០២០៤/០៣០ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៤ ។
- **លើកទី២.** ព្រះរាជសារចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៥ របស់ព្រះមហាក្សត្រ **នរោត្តម សីហមុនី** ព្រឹទ្ធសភាបានបន្តនីតិវិធីបោះឆ្នោតសម្ងាត់ក្នុងសម័យប្រជុំលើកទី៩ នាថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០០៥ ដោយមានសំឡេងគាំទ្រចំនួន ៤៨សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។ ប្រកាសបន្តនីតិកាលរយៈពេល ០១ឆ្នាំទៀត (គិតចាប់ពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៥ ដល់ព្រឹទ្ធសភានីតិកាលទី២ ចូលកាន់តំណែង នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦) តាមព្រះរាជក្រឹត្យៈ នស/រកត/០២០៥/០៧០ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៥ ។

ក្នុងនីតិកាលទី១នេះ ព្រឹទ្ធសភាបានផ្តួចផ្តើមគំនិតស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំលើកទី២ នីតិកាលទី៣ ហើយព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់យល់ស្របលើទម្រង់ និងគតិច្បាប់ទាំងស្រុង នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំលើកទី៩ នីតិកាលទី១ ។ បន្ទាប់មកក្រុមប្រឹក្សា

ធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៧០/០០២/២០០៥ កបធ.ច ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ។ ច្បាប់នេះត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/ ០៦០៥/០២០ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៥ ។

ព្រឹទ្ធសភានីតិកាលទី២ (២០០៦-២០១២) កើតឡើងដោយការបោះឆ្នោតអសកល នាថ្ងៃអាទិត្យ ទី២២ ខែមករា ឆ្នាំ២០០៦ សម្រាប់រយៈពេល៦ឆ្នាំ ។ នីតិកាលទី២ សមាជិកព្រឹទ្ធសភាមានចំនួន ៦១រូប ដូចនីតិកាលទី១ (០២រូបចាត់តាំងដោយព្រះមហាក្សត្រ ០២រូបជ្រើសតាំងដោយរដ្ឋសភា និង ៥៧រូបជ្រើសតាំងដោយការបោះឆ្នោត) ក្នុងនោះមានសមាជិកា ០៩រូប ។ ក្នុង៥៧រូប ដែលជ្រើសតាំង ដោយការបោះឆ្នោតមាន ៤៥រូបមកពីគណបក្សប្រជាជនកម្ពុជា ១០រូបមកពីគណបក្សហ៊្វុនស៊ិនប៉ិច និង ០២រូបមកពីគណបក្សសមរង្ស៊ី ។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ បានប្រព្រឹត្តទៅនាថ្ងៃ អាទិត្យ ទី ២៩ ខែ មករា ឆ្នាំ ២០១២ ។ សម្រាប់នីតិកាលទី៣នេះ សមាជិកព្រឹទ្ធសភាមានចំនួន ៦១រូប ដូច នីតិកាលទី១ និងនីតិកាលទី២ ក្នុងនោះមានសមាជិកាចំនួន ១០រូប (មកពីគណបក្សប្រជាជនកម្ពុជា ០៦រូប សមរង្ស៊ី ០៣រូប និងជ្រើសតាំងដោយរដ្ឋសភា ០១រូប) ។

១- ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា

១.១.ការរៀបចំព្រឹទ្ធសភា

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអង្គការដឹកនាំកំពូលរបស់ព្រឹទ្ធសភា ដឹកនាំដោយ ប្រធានព្រឹទ្ធសភា ហើយមានអនុប្រធានទាំងពីរ និងប្រធានគណកម្មការនានារបស់ព្រឹទ្ធសភាជាសមាជិក។

ព្រឹទ្ធសភាមានគណៈកម្មការនានាចំនួន១០ ៖

១-គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត

២-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

៣-គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និង បរិស្ថាន

៤-គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារ សាធារណៈ

៥-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

៦- គណៈកម្មការនីតិកម្ម និងយុត្តិធម៌

៧-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍

៨-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះ បណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

៩-គណៈកម្មការ សាធារណៈការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១០-គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ ។

សម្គាល់: គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ ជាគណៈកម្មការថ្មី កើតឡើងតាមរយៈការធ្វើវិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី៣ ដែលប្រកាសឲ្យប្រើតាមសេចក្តីសម្រេចលេខ ០៩១/០៩១៤/ពស.សរ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ដោយយោងតាមស្មារតី នៃកិច្ចព្រមព្រៀងស្តីពីការរៀបចំឡើងវិញនូវក្បាលម៉ាស៊ីនដឹកនាំព្រឹទ្ធសភា ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ និងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤ ។

១.២.ការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភាប្រជុំជាសាមញ្ញ២ដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗមានចិរវេលាយ៉ាងតិច៣ខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ (មាត្រា១០៧ថ្មី នៃ រដ្ឋធម្មនុញ្ញ)។

ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើជាសាធារណៈ និងត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិ។ កំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា មានកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ ។ កំណត់ហេតុទាំងអស់ត្រូវរក្សាទុកនៅក្នុងបណ្ណសារដ្ឋានព្រឹទ្ធសភា។

ព្រឹទ្ធសភា អាចកោះប្រជុំជាសម្ងាត់បានតាមសំណើសុំពីប្រធាន ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់យ៉ាងតិច ឬពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា (មាត្រា១១១ថ្មី (ពីរ) នៃ រដ្ឋធម្មនុញ្ញ)។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបានលុះត្រាតែមាន ៖

ក- កូរ៉ុមលើសពីពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ខ- កូរ៉ុមលើសពីពាក់កណ្តាល នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

កូរ៉ុម ត្រូវតែមានគ្រប់ចំនួននៅពេលបើកការប្រជុំ និងនៅពេលអនុម័ត ។

បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល ៣០នាទី ក្រោយពេលកំណត់ចាប់ផ្តើមការប្រជុំ ប្រធានព្រឹទ្ធសភាត្រូវលើកពេលប្រជុំ (ប្រការ៨១ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)។

២- តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភា ជាចំណែកមួយ នៃអង្គនីតិប្បញ្ញត្តិរបស់ជាតិ ដែលបានរួមចំណែកក្នុងដំណើរការប្រជាធិបតេយ្យ ភារូបនីយកម្មសង្គម និងការកសាងកម្ពុជាជានីតិរដ្ឋ ហើយបានរួមវិភាគទាននៅក្នុងដំណើរការស្ថេរភាពនីយកម្មជីវភាពនយោបាយរបស់ជាតិដែលជាស្នូលនៃការពង្រឹងនយោបាយ បង្រួបបង្រួម ផ្សះផ្សាជាតិ និងការអភិវឌ្ឍ ។

ព្រឹទ្ធសភា មានការកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល (រដ្ឋធម្មនុញ្ញ មាត្រា១១២ថ្មី) ។

ព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមជាលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួង ដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ។ បើជាការប្រញាប់រយៈពេលនោះ ត្រូវបន្តយមកនៅត្រឹមតែប្រាំថ្ងៃ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះក្នុងរយៈពេល ដែលមាន កំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅ ប្រកាសឱ្យប្រើ។

បើព្រឹទ្ធសភាសុំឱ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភា ត្រូវយកមក ពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភា ត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែល ព្រឹទ្ធសភាសុំឱ្យកែសម្រួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ។ រយៈពេល នេះ ត្រូវបន្តយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យ នោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និងព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាច នឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ ។ រយៈពេលនេះ ត្រូវបន្តយមកត្រឹមដប់ ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ជាលើកទី២នេះ រដ្ឋសភា ត្រូវអនុម័តដោយ វិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានសម្រេចដូចខាងលើនេះហើយនោះ នឹងត្រូវ បានយកទៅប្រកាសឱ្យប្រើ (រដ្ឋធម្មនុញ្ញ មាត្រា១១៣ថ្មី)។

៣. តាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា

ព្រឹទ្ធសភា និងរដ្ឋសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិដូចគ្នា តែរដ្ឋសភា និងព្រឹទ្ធ-សភា មានអត្តសញ្ញាណ និងសមត្ថកិច្ចខុសគ្នាអាស្រ័យដោយ ៖

១-ប្រតិព

- តំណាងរាស្ត្រទាំងអស់ ត្រូវជ្រើសតាំងដោយការបោះឆ្នោតសកល ដោយប្រជារាស្ត្រតាម មណ្ឌលរាជធានី-ខេត្ត សំរាប់រយៈពេល៥ ឆ្នាំ។
- សមាជិកព្រឹទ្ធសភា ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល ដោយក្រុមប្រឹក្សាឃុំ-សង្កាត់ និងតំណាងរាស្ត្រក្នុងតំណែង តាមភូមិភាគសម្រាប់រយៈពេល៦ឆ្នាំ។ រួមជាមួយនោះ មាន២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និង២រូបទៀតត្រូវបានជ្រើសតាំងដោយរដ្ឋសភា។

ដូច្នេះលក្ខណៈពិសេសរបស់ព្រឹទ្ធសភា គឺព្រឹទ្ធសភាកើតដោយការបោះឆ្នោតជ្រើសតាំងផង និងដោយការចាត់តាំងផង។

២-នាពតំណាង

- តំណាងរាស្ត្រ៖ ជាតំណាងរបស់ប្រជាពលរដ្ឋទូទៅជាម្ចាស់ឆ្នោតក្នុងមណ្ឌល។ បេក្ខជនតំណាងរាស្ត្រ មានអាយុយ៉ាងតិច ២៥ឆ្នាំ។
- សមាជិកព្រឹទ្ធសភា៖ ភាគច្រើនជាតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាម្ចាស់ឆ្នោតនៅក្នុងភូមិភាគ។ ប៉ុន្តែក៏មានតំណាងព្រះមហាក្សត្រ២រូប និង២រូបទៀតជ្រើសតាំងដោយរដ្ឋសភា។ វត្តមាននៃតំណាងស្ថាប័នជាន់ខ្ពស់ទាំងពីរនេះ រួមទាំងភាពជាតំណាងសមូហភាពដែនដី ធ្វើឱ្យព្រឹទ្ធសភាមានតួនាទីពិសេស ជាស្ពានតភ្ជាប់អំណាចរដ្ឋពីថ្នាក់លើទៅថ្នាក់មូលដ្ឋានជាប់នឹងប្រជារាស្ត្រ។
- បេក្ខជនសមាជិកព្រឹទ្ធសភា មានអាយុយ៉ាងតិច ៤០ឆ្នាំ។

កំណត់សម្គាល់ :

- ភាពជាតំណាងខុសគ្នា ការយកចិត្តទុកដាក់ក៏ខុសគ្នា។
- មណ្ឌលរបស់តំណាងរាស្ត្រ ជារាជធានី ខេត្ត។
- មណ្ឌលរបស់សមាជិកព្រឹទ្ធសភា ជាភូមិភាគ ដែលភាគច្រើនជាការប្រមូលផ្តុំខេត្ត ចាប់ពីពីរឡើងទៅ។
- ភាពខុសគ្នាខាងអាយុពុំមែនដោយអត់ហេតុផលឡើយ។ ភាពចាស់ទុំខាងនយោបាយ បទពិសោធន៍ ស្មារតីទទួលខុសត្រូវ និងសីលធម៌ខ្ពស់ជាកត្តាចម្បងនៃការជ្រើសរើសសម្រិតសម្រាំងព្រោះសមាជិកព្រឹទ្ធសភា ត្រូវជ្រើសតាំងដោយអ្នកជាប់ឆ្នោត និងចាត់តាំងដោយព្រះមហាក្សត្រ។ នេះក៏ជាចំណុចកត់សម្គាល់អំពីភាពខុសគ្នារវាងសភាទាំងពីរនៅក្នុងការអនុវត្តការងារជាក់ស្តែង ។ ការឱ្យយោបល់ប្រកបដោយគតិបណ្ឌិត ការណែនាំ និងការបង្ហាញផ្លូវជាការយកចិត្តទុកដាក់របស់ព្រឹទ្ធសភា។
- ភាពខុសគ្នាខាងប្រព័ន្ធបោះឆ្នោត អង្គបោះឆ្នោត រយៈពេលនៃនីតិកាលបង្ហាញនូវលក្ខណៈពិសេសផ្ទាល់ និងអត្តសញ្ញាណផ្ទាល់របស់សភានីមួយៗ។

៣-អំណាច

ក-រដ្ឋសភាជ្រើសតាំងរដ្ឋាភិបាល

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល (មាត្រា ៩០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ) និងអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង (មាត្រា៩៨ថ្មី នៃរដ្ឋធម្មនុញ្ញ)។ រដ្ឋសភាអាចត្រូវបានរំលាយមុនផុតនីតិកាល បើសិនរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដង ក្នុងរយៈពេល ១២ខែ។ ព្រឹទ្ធសភា មិនអាចត្រូវរំលាយមុនចប់នីតិកាលបានទេ។

ខ-សិទ្ធិវិសោធនកម្មរដ្ឋធម្មនុញ្ញ

មាត្រា ១៥៣ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ ផ្តល់សិទ្ធិផ្តួចផ្តើមគំនិតសើរើ ឬផ្តួចផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដល់ប្រធានរដ្ឋសភា ឬតាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួន នៃចំនួនសមាជិក

រដ្ឋសភាទាំងមូល ។ រដ្ឋធម្មនុញ្ញពុំបានផ្តល់សិទ្ធិផ្តួចផ្តើមគំនិតនេះដល់ព្រឹទ្ធសភាទេ ។

គ-ការផ្តួចផ្តើមគំនិតធ្វើច្បាប់

សមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភា មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមានដូចគ្នា (មាត្រា ៩១ថ្មី នៃរដ្ឋធម្មនុញ្ញ និងសេចក្តីសម្រេចលេខ: ១៥៥/០០៣/២០១៥ កបធ.ច ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ស្តីពីការបកស្រាយមាត្រា ៩១ថ្មី នៃរដ្ឋធម្មនុញ្ញ) ។ សេចក្តីស្នើច្បាប់ ឬសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលផ្តួចផ្តើមធ្វើដោយសមាជិកព្រឹទ្ធសភា ត្រូវតែបញ្ជូនទៅឱ្យរដ្ឋសភាពិនិត្យ និងអនុម័តជាលើកដំបូង រួចហើយទើបបញ្ជូនមកព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់ស្របតាមមាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ។

ឃ-ការត្រួតពិនិត្យលើរដ្ឋាភិបាល

រដ្ឋសភាមានអំណាចតាមច្បាប់ក្នុងការចោទសួរ ដេញដោល និងអនុម័តញត្តិបន្ទោស ដកហូតតំណែង ឬរំលាយរាជរដ្ឋាភិបាល ។ តែនៅក្នុងការអនុវត្តជាក់ស្តែងក្នុងសភានានា លើពិភពលោក ទោះបីជាមានគណបក្សប្រឆាំងនៅក្នុងរដ្ឋសភាយ៉ាងណាក្តី ការប្រើអំណាចត្រួតពិនិត្យនេះមានប្រសិទ្ធភាពមិនសូវខ្ពស់ទេ ព្រោះរដ្ឋសភាជាអ្នកបង្កើតរដ្ឋាភិបាល ហើយរបបសំឡេងភាគច្រើនតែងតែគាំទ្ររដ្ឋាភិបាល។ ចរិតរបស់រដ្ឋសភា ជាទូទៅជាប់ជំពាក់នឹងនយោបាយ ដោយមានជម្រើស២: គាំទ្រ ឬក៏ប្រឆាំងរដ្ឋាភិបាល ។ សម្រាប់ព្រឹទ្ធសភា ចរិតទូទៅគឺមិនមែនប្រឆាំង ឬគាំទ្ររដ្ឋាភិបាលឡើយ ផលិតច្បាប់ឱ្យបានល្អជាគោលដៅអាទិភាពរបស់ព្រឹទ្ធសភា ។ ការផលិតច្បាប់បានល្អ គឺមិនចំណុះបរិយាកាសនយោបាយ និងកាល:ទេស:ឡើយ។ ព្រឹទ្ធសភាមិនប្រឈមនឹងរដ្ឋាភិបាលដូចរដ្ឋសភា ដោយប្រើញត្តិបន្ទោស ដើម្បីដកហូតមុខតំណែងសមាជិករដ្ឋាភិបាល ឬរំលាយរដ្ឋាភិបាលឡើយ។ ជាទូទៅព្រឹទ្ធសភាជាកូនជញ្ជីងមួយដើម្បីធ្វើឱ្យច្បាប់មានតុល្យភាព ដែលអាចទទួលយកបានពីរដ្ឋសភា រដ្ឋាភិបាល និងពីសំណាក់ប្រជាពលរដ្ឋ ។ គ្មានស្ថាប័នណាមួយអាចប្រឡូកនៅក្នុងការដ្ឋាននេះបានឡើយ លើកលែងតែក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានសិទ្ធិសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ មុននឹងប្រកាសឱ្យប្រើ ហើយសម្រាប់តែច្បាប់ធម្មនុញ្ញ និងច្បាប់រៀបចំអង្គការតែប៉ុណ្ណោះ ។ ដូច្នេះច្បាប់ជាទូទៅ ចាំបាច់ត្រូវការសំឡេងពិនិត្យ និងឱ្យយោបល់របស់ព្រឹទ្ធសភា ។

ផ្តើមចេញពីចរិតខុសគ្នានេះ យោបល់ និងការឆ្លុះបញ្ចាំងរបស់ព្រឹទ្ធសភាអាចខុសប្លែកគ្នាពីរដ្ឋសភា ។ យោបល់ និងការឆ្លុះបញ្ចាំងរបស់ព្រឹទ្ធសភា មានលក្ខណៈស្ថាបនាតាមរយៈការសិក្សាស្រាវជ្រាវ វាយតម្លៃ កំណត់នូវចក្ខុវិស័យ និងផ្តល់អនុសាសន៍កែលម្អ។

ង-អំណាចសម្រេចចិត្ត

រដ្ឋសភា និងព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ (រដ្ឋធម្មនុញ្ញ មាត្រា១១៦ថ្មី)។

៨-បទប្បញ្ញត្តិពិសេស ចែងក្នុងរដ្ឋធម្មនុញ្ញ

ក-ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងពេលព្រះមហាក្សត្រទ្រង់អវត្តមាន (រដ្ឋធម្មនុញ្ញ មាត្រា៣០ថ្មី)។ នៅពេលព្រះមហាក្សត្រទ្រង់ចូលទិវង្គត ឬទ្រង់ប្រឈួនជាទម្ងន់ ប្រធាន

ព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ នៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ មាត្រា១១ថ្មី និងមាត្រា១២ថ្មី)។ នេះជាការធានាស្ថិរភាព និងនិរន្តរភាពរបស់រដ្ឋ។

ខ-ប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា ជាសមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិ (រដ្ឋធម្មនុញ្ញ មាត្រា១៣ថ្មី)។

គ-នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា (រដ្ឋធម្មនុញ្ញ មាត្រា២២ ថ្មី)។

ឃ-ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា (រដ្ឋធម្មនុញ្ញ មាត្រា២៤ថ្មី)។

ង-ព្រឹទ្ធសភា មានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល (រដ្ឋធម្មនុញ្ញ មាត្រា ១១២ថ្មី)។ នេះជាការធានាប្រក្រតីភាព នៃជីវភាពរបស់រដ្ឋ ដើម្បីចៀសវាងវិបត្តិតូច និងធំទាំងឡាយ។

ច-ការស្នើពិនិត្យធម្មនុញ្ញភាពនៃច្បាប់៖ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត ទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងច្បាប់នោះត្រូវយកទៅប្រកាសឱ្យប្រើ (រដ្ឋធម្មនុញ្ញមាត្រា ១៤០ថ្មី)។

ក្រោយពីច្បាប់ណាមួយ ត្រូវបានប្រកាសឲ្យប្រើប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួនអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យពីធម្មនុញ្ញភាពនៃច្បាប់នោះ (រដ្ឋធម្មនុញ្ញមាត្រា ១៤១ ថ្មី)។

ឆ-រដ្ឋធម្មនុញ្ញមាត្រា ១១៤ថ្មី (មួយ) អនុញ្ញាតឲ្យព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗ តាមការចាំបាច់។

ជ-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា មាត្រា៤ ចែងថាប្រធានព្រឹទ្ធសភាជាប្រធានសមាជ ។

៤-នីតិវិធីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬ បញ្ហាទាំងពួង

បញ្ញត្តិជាមូលដ្ឋាន ៖

-រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា (មាត្រា១១៣ថ្មី)


-សេចក្តីសំរេចលេខ ០៣៦ /០០២/២០០០ កបធ-ច ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

-បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

ចំណុចគន្លឹះ

- លើការដ្ឋានកសាងច្បាប់ រដ្ឋសភា និងព្រឹទ្ធសភាដើរតួនាទីបំពេញអោយគ្នាទៅវិញទៅមក ដែលមានចរិតជាប្រព័ន្ធការងារបន្តគ្នា ដោយពុំជាន់ការងារគ្នា ឬដោយប្រកួតប្រជែងរវាងគ្នាឡើយជាអាទិ៍៖
  ១. រដ្ឋសភារ៉ាប់រងតួនាទីពាក់ព័ន្ធនឹងដំណើរផលិតកម្មច្បាប់ (Production) ។
  ២. ព្រឹទ្ធសភាបន្តការងារពីរដ្ឋសភា គឺការងារត្រួតពិនិត្យគុណភាពនៃផលិតផល (ច្បាប់) ដែលរដ្ឋសភាបានអនុម័ត ។
- ការងារផលិតកម្ម និងការងារត្រួតពិនិត្យគុណភាពផលិតផលគឺជាការងារសារវ័ន្ត នៃដំណើរការកសាងច្បាប់ (ផលិតកម្ម) ។

គំនូសបំព្រួញ នីតវិធីនៃការពិនិត្យ និងអនុម័តច្បាប់



កំណត់សម្គាល់ ៖ ដំណើរនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ៖

(១). រាជរដ្ឋាភិបាល

(២). ដំណើរការក្នុងសភានីមួយៗ

(៣). ការបង្វិលទៅបង្វិលមកវាងសភាទាំងពីរ

៥- គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

គណៈកម្មាធិការអចិន្ត្រៃយ៍មាន ៖

-ប្រធានព្រឹទ្ធសភា

-អនុប្រធានទាំងពីរ របស់ព្រឹទ្ធសភា

-ប្រធានគណៈកម្មការនានារបស់ព្រឹទ្ធសភា។

ប្រធានព្រឹទ្ធសភា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។

(យោង៖ប្រកា១៣-បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី៣)

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាមានតួនាទីភារកិច្ចដូចតទៅ ៖

ក-ដឹកនាំ ចាត់ចែង និងពិនិត្យសម្រេចរាល់ការងារ សកម្មភាពផ្សេងៗរបស់ព្រឹទ្ធសភា ក្នុងលក្ខខណ្ឌកំណត់នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

ខ-ចាត់ចែងការងាររបស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា។

គ-រៀបចំរបៀបវារៈសម្រាប់ពេលប្រជុំព្រឹទ្ធសភានីមួយៗ។

ឃ-រៀបចំសមាសភាពលេខាធិការពីររូប សម្រាប់សម័យប្រជុំបន្ទាប់ ដើម្បីដាក់ជូនអង្គប្រជុំព្រឹទ្ធសភាអនុម័ត។

ង-ធានាការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ច-ធានាការគ្រប់គ្រង និងការចំណាយថវិកាព្រឹទ្ធសភាឲ្យប្រព្រឹត្តទៅបានត្រឹមត្រូវតាមការកំណត់ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ឆ-ធានាការផ្តល់គ្រឿងឥស្សរិយយសជូនសមាជិកព្រឹទ្ធសភា។

ជ-ធានាការអនុវត្តវិន័យក្នុងព្រឹទ្ធសភា។

ឈ-លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចលើការស្នើចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនសមាជិកព្រឹទ្ធសភាណាមួយ។ ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា មានសិទ្ធិយល់ព្រមលើការស្នើចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនសមាជិកណាមួយនៃព្រឹទ្ធសភា។ សេចក្តីសម្រេចរបស់គណៈកម្មការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខដើម្បីអនុម័ត។

ញ-លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចលើការផ្អាកការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយ។

ដ-លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចអំពីការព្យួរអភ័យឯកសិទ្ធិសភា ការប្រគល់ជូនវិញនូវអភ័យឯកសិទ្ធិសភា ការបោះបង់ចោលការងារ វិសមិតភាព និងការប្រាសចាកសមាជិកព្រឹទ្ធសភា។

(យោង៖ប្រកា១៤-បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី៣)

៦- បញ្ជីរាយនាមសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)

តាមលំដាប់អក្ខរក្រមខ្មែរ

ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	មកពី
១	ឯកឧត្តម **កុក អាន**	ប្រុស	០៧/០៧/១៩៥៤	
២	លោកជំទាវ **កែវ ម៉ាលី**	ស្រី	០១/០២/១៩៥៥	
៣	ឯកឧត្តម **ខៀវ មុត**	ប្រុស	៣០/០៨/១៩៥១	
៤	ឯកឧត្តម **គង់ សារាជ**	ប្រុស	២២/០៨/១៩៤៧	
៥	ឯកឧត្តម **ចាន់ ណារ៉ែត**	ប្រុស	១៥/០១/១៩៤៧	
៦	ឯកឧត្តម **ចេម គីមអ៊ាង**	ប្រុស	០៧/០៣/១៩៦៣	
៧	ឯកឧត្តម **ឆាត់ លឿម**	ប្រុស	១០/០៨/១៩៣៦	
៨	ឯកឧត្តម **ជា ដេដ្ឋ**	ប្រុស	១៣/០១/១៩៤៨	
៩	ឯកឧត្តម **ជា សុន**	ប្រុស	០២/០២/១៩៣៩	
១០	លោកជំទាវ **ជិន សុចិម**	ស្រី	០១/០៦/១៩៥១	
១១	ឯកឧត្តម **ជុំ វាច**	ប្រុស	១០/០៥/១៩៥២	
១២	ឯកឧត្តម **ឈិត គឹមយាត**	ប្រុស	០៨/០៦/១៩៤៧	
១៣	លោកជំទាវ **ឈូក ឈឹម**	ស្រី	១០/១០/១៩៥៤	
១៤	ឯកឧត្តម **ឈួន សឿន**	ប្រុស	០៥/០៥/១៩៤៥	
១៥	ឯកឧត្តម **ឈួន ឡេង**	ប្រុស	០៥/០២/១៩៥៣	
១៦	លោកជំទាវ **ថាក់ ឡានី**	ស្រី	២០/០៧/១៩៥៥	
១៧	ឯកឧត្តម **ថុង ចន់**	ប្រុស	០៦/០៨/១៩៤១	
១៨	ឯកឧត្តម **ទាវ វណ្ណុល**	ប្រុស	១០/០៨/១៩៥៥	
១៩	លោកជំទាវ **ទី ម៉ូរ៉ាស៊ី**	ស្រី	០១/០៨/១៩៣៩	
២០	ឯកឧត្តម **ទឹម ថន**	ប្រុស	៣០/០៩/១៩៥១	
២១	ឯកឧត្តម **នេត ចន**	ប្រុស	០១/០១/១៩៤៧	
២២	ឯកឧត្តម **នួន សាមិន**	ប្រុស	១៨/១០/១៩៥១	
២៣	ឯកឧត្តម **នៃ ប៉ែណា**	ប្រុស	០៨/០៥/១៩៤៨	
២៤	ឯកឧត្តម **ប៉ូ ថង**	ប្រុស	១៥/០៨/១៩៣៨	
២៥	ឯកឧត្តម **ប្រាក់ ចំរើន**	ប្រុស	២៤/១២/១៩៥៤	
២៦	ឯកឧត្តម **ពុធ ខូវ**	ប្រុស	១០/០៥/១៩៤៩	
២៧	លោកជំទាវ **ពុំ ស៊ីចាន់**	ស្រី	០១/១១/១៩៤៧	
២៨	ឯកឧត្តម **ម៉ម ប៊ុនឆាង**	ប្រុស	០៧/១១/១៩៥៦	
២៩	ឯកឧត្តម **ម៉ុង ឫទ្ធី**	ប្រុស	១១/០៧/១៩៥៤	

៣០	ឯកឧត្តម ម៉ែន ស៊ីផាន់	ប្រុស	០៥/០១/១៩៥៤	
៣១	ឯកឧត្តម ម៉ាន់ ឈឿន	ប្រុស	០៧/០៦/១៩៥០	
៣២	លោកជំទាវ មាន សំអាន	ស្រី	១៦/០៦/១៩៥៦	
៣៣	ឯកឧត្តម យ៉ង់ សែម	ប្រុស	០១/១២/១៩៤៣	
៣៤	ឯកឧត្តម យឹម សេត	ប្រុស	០៥/០១/១៩៥១	
៣៥	ឯកឧត្តម យឹម ឃុនឈឿន	ប្រុស	១៥/១១/១៩៥៦	
៣៦	ឯកឧត្តម យូ ស៊ាងហោង	ប្រុស	១០/០៤/១៩៧០	
៣៧	ឯកឧត្តម លី យ៉ុងផាត់	ប្រុស	០៧/០១/១៩៥៨	
៣៨	លោកជំទាវ លី នារី	ស្រី	០១/០១/១៩៤៣	
៣៩	ឯកឧត្តម វ៉ាន់ ឆុង	ប្រុស	០១/០៩/១៩៥៤	
៤០	ឯកឧត្តម វ៉ាន់ ម៉ាត់	ប្រុស	០១/០១/១៩៤៨	
៤១	ឯកឧត្តម ស៊ឹម កា	ប្រុស	១៩/០៤/១៩៤៨	
៤២	ឯកឧត្តម ស៊ើយ កែវ	ប្រុស	០៣/០៦/១៩៣៧	
៤៣	សម្តេចវិបុលសេនាភក្តី សាយ ឈុំ	ប្រុស	០៥/០២/១៩៤៥	
៤៤	ឯកឧត្តម សួន លន់	ប្រុស	១៧/០៤/១៩៤៣	
៤៥	ឯកឧត្តម សោ ចាន់ដេត	ប្រុស	០៥/០៥/១៩៧០	
៤៦	ឯកឧត្តម សេង ម៉ារឌី	ប្រុស	២៤/០១/១៩៦៧	
៤៧	ឯកឧត្តម សួន វ៉ាន់ឡេង	ប្រុស	០៩/០៣/១៩៦៥	
៤៨	ឯកឧត្តម ហុង ងួហាយ	ប្រុស	២៧/១០/១៩៣៩	
៤៩	ឯកឧត្តម ហុង សុខហួរ	ប្រុស	១៤/០៣/១៩៥៦	
៥០	ឯកឧត្តម ហោង ង៉ូ	ប្រុស	០៥/០២/១៩៧០	
៥១	លោកជំទាវ ឡាក់ អូន	ស្រី	២១/១២/១៩៤៥	
៥២	ឯកឧត្តម ឡាយ អ៊ីពិសិទ្ធិ	ប្រុស	០៥/០១/១៩៤៨	
៥៣	ឯកឧត្តម ឡាវ ម៉េងឃីន	ប្រុស	០១/០១/១៩៤៤	
៥៤	លោកជំទាវ ឡាយ ងូនី	ស្រី	២០/០៣/១៩៥០	
៥៥	ឯកឧត្តម អន ស៊ុំ	ប្រុស	២៥/១១/១៩៥០	
៥៦	ឯកឧត្តម អ៊ុក គង់	ប្រុស	២០/០៥/១៩៤៩	
៥៧	ឯកឧត្តម អ៊ុក ឃុនឈឿន	ប្រុស	០៥/០៣/១៩៤៣	
៥៨	ឯកឧត្តម អ៊ុច ឆី	ប្រុស	៣០/០៦/១៩៤៩	
៥៩	ឯកឧត្តម អ៊ុំ ម៉ាឡូរីន	ប្រុស	០៤/០៣/១៩២៤	
៦០	ឯកឧត្តម អាំ សំអាត	ប្រុស	០៣/០៨/១៩៥០	
៦១	ឯកឧត្តម អៀវ បណ្ណាការ	ប្រុស	២១/០២/១៩៣១	

៧- បញ្ជីរាយនាមសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)

តាមលំដាប់អាយុ

ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	មកពី
១	ឯកឧត្តម **អ៊ុំ ម៉ាន្នូរិន**	ប្រុស	០៣/០៤/១៩២៤	
២	ឯកឧត្តម **អៀវ បណ្ណាការ**	ប្រុស	០២/២១/១៩៣១	
៣	ឯកឧត្តម **ឆាត់ ឈឿម**	ប្រុស	១០/០៨/១៩៣៦	
៤	ឯកឧត្តម **ស៊ើយ កែវ**	ប្រុស	០៣/០៦/១៩៣៧	
៥	ឯកឧត្តម **ថ្ង ថង**	ប្រុស	១៥/០៨/១៩៣៨	
៦	ឯកឧត្តម **ជា សុន**	ប្រុស	០២/០២/១៩៣៩	
៧	លោកជំទាវ **ធី ម៉ូរ៉ាស៊ី**	ស្រី	០១/០៨/១៩៣៩	
៨	ឯកឧត្តម **ហុង ងួហាយ**	ប្រុស	២៧/១០/១៩៣៩	
៩	ឯកឧត្តម **ថុង ចន់**	ប្រុស	០៦/០៨/១៩៤១	
១០	ឯកឧត្តម **អ៊ុក ប៊ុនឈឿន**	ប្រុស	០៥/០៣/១៩៤៣	
១១	ឯកឧត្តម **សួន លន់**	ប្រុស	១៧/០៤/១៩៤៣	
១២	ឯកឧត្តម **យ៉ង់ សែម**	ប្រុស	០១/១២/១៩៤៣	
១៣	លោកជំទាវ **លី ឆារី**	ស្រី	០១/០១/១៩៤៣	
១៤	ឯកឧត្តម **ឡាវ ម៉េងឃីន**	ប្រុស	០១/០១/១៩៤៤	
១៥	សម្តេចវិបុលសេនាភក្តី **សាយ ឈុំ**	ប្រុស	០៥/០២/១៩៤៥	
១៦	ឯកឧត្តម **ឈួន សឿន**	ប្រុស	០៥/០៥/១៩៤៥	
១៧	លោកជំទាវ **ឡាក់ អូន**	ស្រី	២១/១២/១៩៤៥	
១៨	ឯកឧត្តម **ឆេង ចន**	ប្រុស	០១/០១/១៩៤៧	
១៩	ឯកឧត្តម **ចាន់ ណារ៉ែត**	ប្រុស	១៥/០១/១៩៤៧	
២០	ឯកឧត្តម **ឈិត គីមយាត**	ប្រុស	០៨/០៦/១៩៤៧	
២១	ឯកឧត្តម **គង់ សារ៉ង**	ប្រុស	២២/០៨/១៩៤៧	
២២	លោកជំទាវ **ពុំ ស៊ីចាន់**	ស្រី	០១/១១/១៩៤៧	
២៣	ឯកឧត្តម **ង៉ាន់ ម៉ាត់**	ប្រុស	០១/០១/១៩៤៨	
២៤	ឯកឧត្តម **ឡាយ អ៊ីតិសិទ្ធិ**	ប្រុស	០៥/០១/១៩៤៨	
២៥	ឯកឧត្តម **ជា ដេដ្ឋ**	ប្រុស	១៣/០១/១៩៤៨	
២៦	ឯកឧត្តម **ស៊ឹម កា**	ប្រុស	១៩/០៤/១៩៤៨	
២៧	ឯកឧត្តម **នៃ ប៉ែណា**	ប្រុស	០៨/០៥/១៩៤៨	
២៨	ឯកឧត្តម **ពុធ ខូវ**	ប្រុស	១០/០៥/១៩៤៩	
២៩	ឯកឧត្តម **អ៊ុក គង់**	ប្រុស	២០/០៥/១៩៤៩	

៣០	ឯកឧត្តម អ៊ុច ទី	ប្រុស	៣០/០៦/១៩៤៩	
៣១	លោកជំទាវ ឡាយ ឫនី	ស្រី	២០/០៣/១៩៥០	
៣២	ឯកឧត្តម ម៉ាន់ ឈឿន	ប្រុស	០៧/០៦/១៩៥០	
៣៣	ឯកឧត្តម អាំ សំអាត	ប្រុស	០៣/០៨/១៩៥០	
៣៤	ឯកឧត្តម អន ស៊ុំ	ប្រុស	២៥/១១/១៩៥០	
៣៥	ឯកឧត្តម ឃីម សេត	ប្រុស	០៥/០១/១៩៥១	
៣៦	លោកជំទាវ ជិន សុចិម	ស្រី	០១/០៦/១៩៥១	
៣៧	ឯកឧត្តម ខៀវ មុត	ប្រុស	៣០/០៨/១៩៥១	
៣៨	ឯកឧត្តម ទឹម ផន	ប្រុស	៣០/០៩/១៩៥១	
៣៩	ឯកឧត្តម ឆួន សាមិន	ប្រុស	១៨/១០/១៩៥១	
៤០	ឯកឧត្តម ជុំ ឥច	ប្រុស	១០/០៥/១៩៥២	
៤១	ឯកឧត្តម ឈួន ឡេច	ប្រុស	០៥/០២/១៩៥៣	
៤២	ឯកឧត្តម ម៉ែន ស៊ីផាន់	ប្រុស	០៥/០១/១៩៥៤	
៤៣	ឯកឧត្តម ភុក អាន	ប្រុស	០៧/០៧/១៩៥៤	
៤៤	ឯកឧត្តម ម៉ុច ឫទ្ធី	ប្រុស	១១/០៧/១៩៥៤	
៤៥	ឯកឧត្តម ង៉ាន់ ឆុង	ប្រុស	០១/០៩/១៩៥៤	
៤៦	លោកជំទាវ ឈុក ឈីម	ស្រី	១០/១០/១៩៥៤	
៤៧	ឯកឧត្តម ប្រាក់ ចំរើន	ប្រុស	២៤/១២/១៩៥៤	
៤៨	លោកជំទាវ កែវ ម៉ាលី	ស្រី	០១/០២/១៩៥៥	
៤៩	លោកជំទាវ ថាក់ ឡានី	ស្រី	២០/០៧/១៩៥៥	
៥០	ឯកឧត្តម ឆាវ វណ្ណុល	ប្រុស	១០/០៨/១៩៥៥	
៥១	ឯកឧត្តម ហុង សុខហួរ	ប្រុស	១៨/០៣/១៩៥៦	
៥២	លោកជំទាវ ហាន សំអាន	ស្រី	១៦/០៦/១៩៥៦	
៥៣	ឯកឧត្តម ឃីម ឃុនឃឿន	ប្រុស	១៥/១១/១៩៥៦	
៥៤	ឯកឧត្តម ម៉ម ប៊ុនឆាង	ប្រុស	០៧/១១/១៩៥៦	
៥៥	ឯកឧត្តម លី យ៉ុងផាត់	ប្រុស	០៧/០១/១៩៥៨	
៥៦	ឯកឧត្តម ចេម គីមអ៊ាង	ប្រុស	០៧/០៣/១៩៦៣	
៥៧	ឯកឧត្តម សួន ង៉ាន់ឡេច	ប្រុស	០៩/០៣/១៩៦៥	
៥៨	ឯកឧត្តម សេង ង៉ារី	ប្រុស	២៤/០១/១៩៦៧	
៥៩	ឯកឧត្តម ហេង ង៉ោ	ប្រុស	០៥/០២/១៩៧០	
៦០	ឯកឧត្តម ឃូ ស៊ាងហេង	ប្រុស	១០/០៤/១៩៧០	
៦១	ឯកឧត្តម សោ ចាន់ដេត	ប្រុស	០៥/០៥/១៩៧០	

៨- បញ្ជីរាយនាមសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)

តាមមណ្ឌលតូមិនាគ

ក. មណ្ឌលភូមិភាគ ទី ១ (រាជធានីភ្នំពេញ)

អាសនៈរួម ៦	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៤ អាសនៈ	១	ឯកឧត្តម **ស៊ឹម កា**	ប្រុស	១៩/០៤/១៩៤៨	
	២	ឯកឧត្តម **ជា ដេដ្ឋ**	ប្រុស	១៣/០១/១៩៤៨	
	៣	លោកជំទាវ **ពុំ ស៊ីចាន់**	ស្រី	០១/១១/១៩៤៧	
	៤	ឯកឧត្តម **ម៉ាន់ ឈឿន**	ប្រុស	០៧/០៦/១៩៥០	
គណបក្ស សម រង្ស៊ី ២ អាសនៈ	៥	លោកជំទាវ **លី ឆារី**	ស្រី	០១/០១/១៩៤៣	
	៦	ឯកឧត្តម **ចេម គីមអ៊ាង**	ប្រុស	០៧/០៣/១៩៦៣	

ខ. មណ្ឌលភូមិភាគ ទី ២ (ខេត្តកំពង់ចាម)

អាសនៈរួម ៨	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៦ អាសនៈ	១	ឯកឧត្តម **អ៊ុក ប៊ុនឈឿន**	ប្រុស	០៥/០៣/១៩៤៣	
	២	លោកជំទាវ **ឈុក ឈឹម**	ស្រី	១០/១០/១៩៥៤	
	៣	ឯកឧត្តម **ហោ ចូរ៉ា**	ប្រុស	០៥/០២/១៩៧០	
	៤	ឯកឧត្តម **ឈិត គឹមយាត**	ប្រុស	០៨/០៦/១៩៤៧	
	៥	ឯកឧត្តម **ឆួន សាមិន**	ប្រុស	១៨/១០/១៩៥១	
	៦	ឯកឧត្តម **ខ៉ាន់ ម៉ាត់**	ប្រុស	០១/០១/១៩៤៨	
គណបក្ស សម រង្ស៊ី ២ អាសនៈ	៧	លោកជំទាវ **ថាក់ ឆ្លានី**	ស្រី	២០/០៧/១៩៥៥	
	៨	ឯកឧត្តម **សួន ខ៉ាន់ឆេង**	ប្រុស	០៩/០៣/១៩៦៥	

គ. មណ្ឌលភូមិភាគ ទី ៣ (ខេត្តកណ្តាល)

អាសនៈរួម ៥	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៤ អាសនៈ	១	ឯកឧត្តម **ឧេៀ ចន**	ប្រុស	០១/០១/១៩៤៧	
	២	លោកជំទាវ **ឌី ប៊ូរ៉ាស៊ី**	ស្រី	០១/០៨/១៩៣៩	
	៣	ឯកឧត្តម **ឆ្លាវ ម៉េងឃីន**	ប្រុស	០១/០១/១៩៤៤	
	៤	ឯកឧត្តម **ម៉ម ប៊ុនណាង**	ប្រុស	០៧/១១/១៩៥៦	
គណបក្ស សម រង្ស៊ី ១ អាសនៈ	៥	លោកជំទាវ **ឆ្លាយ ចូនី**	ស្រី	២០/០៣/១៩៥០	

ឃ. **មណ្ឌលភូមិភាគ ទី ៤** (ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងខេត្តប៉ៃលិន)

អាសនៈរួម ១០	លរ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៨ អាសនៈ	១	ឯកឧត្តម **ឆាត់ ឈឿម**	ប្រុស	១០/០៨/១៩៣៦	
	២	ឯកឧត្តម **ហុច ឆ្ហាយ**	ប្រុស	២៧/១០/១៩៣៩	
	៣	ឯកឧត្តម **សួន លន់**	ប្រុស	១៧/០៤/១៩៤៣	
	៤	ឯកឧត្តម **អន ស៊ុំ**	ប្រុស	២៥/១១/១៩៥០	
	៥	ឯកឧត្តម **អាំ សំអាត**	ប្រុស	០៣/០៨/១៩៥០	
	៦	ឯកឧត្តម **ចាន់ ណារ៉េត**	ប្រុស	១៥/០១/១៩៤៧	
	៧	ឯកឧត្តម **យឹម សេត**	ប្រុស	០៥/០១/១៩៥១	
	៨	ឯកឧត្តម **អ៊ុក គង់**	ប្រុស	២០/០៥/១៩៤៩	
គណបក្ស សម រង្ស៊ី ២ អាសនៈ	៩	ឯកឧត្តម **ហុច សុខហួរ**	ប្រុស	១៤/០៣/១៩៥៦	
	១០	ឯកឧត្តម **សោ ចាន់ដេត**	ប្រុស	០៥/០៥/១៩៧០	

ង. **មណ្ឌលភូមិភាគ ទី ៥** (ខេត្តតាកែវ កំពត និងខេត្តកែប)

អាសនៈរួម ៧	លរ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៦ អាសនៈ	១	ឯកឧត្តម **នៃ ប៉ែណា**	ប្រុស	០៨/០៥/១៩៤៨	
	២	លោកជំទាវ **ជិន សុខីម**	ស្រី	០១/០៦/១៩៥៦	
	៣	ឯកឧត្តម **កុក អាន**	ប្រុស	០៧/០៧/១៩៥៤	
	៤	ឯកឧត្តម **អ៊ុច ធី**	ប្រុស	៣០/០៦/១៩៤៩	
	៥	ឯកឧត្តម **ម៉ុច ឫទ្ធី**	ប្រុស	១១/០៧/១៩៥៤	
	៦	ឯកឧត្តម **ពុធ ឌូច**	ប្រុស	១០/០៥/១៩៤៩	
គណបក្ស សម រង្ស៊ី ១ អាសនៈ	៧	ឯកឧត្តម **ឆាវ វណ្ណុល**	ប្រុស	១០/០៨/១៩៥៥	

ច. **មណ្ឌលភូមិភាគ ទី ៦** (ខេត្តព្រៃវែង និងស្វាយរៀង)

អាសនៈរួម ៧	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៦ អាសនៈ	១	លោកជំទាវ **ហាន សំអាន**	ស្រី	១៦/០៦/១៩៥៦	
	២	ឯកឧត្តម **ជា សុន**	ប្រុស	០២/០២/១៩៣៩	
	៣	ឯកឧត្តម **ឈួន សឿន**	ប្រុស	០៥/០៥/១៩៤៥	
	៤	ឯកឧត្តម **ម៉ែន ស៊ីថាន់**	ប្រុស	០៥/០១/១៩៥៤	
	៥	ឯកឧត្តម **ទឹម ថន**	ប្រុស	៣០/០៩/១៩៥១	
	៦	ឯកឧត្តម **ឈួន ឡេង**	ប្រុស	០៥/០២/១៩៥៣	
គណបក្ស សម រង្ស៊ី ១ អាសនៈ	៧	ឯកឧត្តម **យឹម ឃុនឃឿន**	ប្រុស	១៥/១១/១៩៥៦	

ឆ. **មណ្ឌលភូមិភាគ ទី៧** (ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ កោះកុង និងខេត្តព្រះសីហនុ)

អាសនៈរួម ៨	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៧ អាសនៈ	១	សម្តេចវិបុលសេនាភក្តី **សាយ ឈុំ**	ប្រុស	០៥/០២/១៩៤៥	
	២	លោកជំទាវ **ឡាក់ អូន**	ស្រី	២១/១២/១៩៤៥	
	៣	ឯកឧត្តម **លី យ៉ុងផាត់**	ប្រុស	០៧/០១/១៩៥៨	
	៤	ឯកឧត្តម **ឡាយ អ៊ីពិសិទ្ធិ**	ប្រុស	០៥/០១/១៩៤៨	
	៥	ឯកឧត្តម **ដុំ ឋន**	ប្រុស	១០/០៥/១៩៥២	
	៦	ឯកឧត្តម **គង់ សារាជ**	ប្រុស	២២/០៨/១៩៤៧	
	៧	ឯកឧត្តម **ថុច ចន់**	ប្រុស	០៦/០៨/១៩៤១	
គណបក្ស សម រង្ស៊ី ១ អាសនៈ	៨	ឯកឧត្តម **ឃួ សុាងហោង**	ប្រុស	១០/០៤/១៩៧០	

ជ. **មណ្ឌលភូមិភាគ ទី ៨** (ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី)

អាសនៈរួម ៦	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៥ អាសនៈ	១	ឯកឧត្តម **ចៀ ថន**	ប្រុស	១៥/០៨/១៩៣៨	
	២	ឯកឧត្តម **យ៉ង់ សែម**	ប្រុស	០១/១២/១៩៤៣	
	៣	ឯកឧត្តម **ស៊ើយ កែវ**	ប្រុស	០៣/០៦/១៩៣៧	
	៤	ឯកឧត្តម **ង៉ាន់ តុច**	ប្រុស	០១/០៩/១៩៥៤	
	៥	លោកជំទាវ **កែវ ម៉ាលី**	ស្រី	០១/០២/១៩៥៥	
គណបក្ស សម រង្ស៊ី ១ អាសនៈ	៦	ឯកឧត្តម **សេង ម៉ារឌី**	ប្រុស	២៤/០១/១៩៦៧	

៩- បញ្ជីរាយនាមសមាជិកព្រឹទ្ធសភា នីតិកាលទី៣ តាមគណបក្ស

១- គណបក្សប្រជាជនកម្ពុជា

ល.រ	គោត្តនាម-នាម	ភេទ	គណបក្ស
១	សម្តេចវិបុលសេនាភក្តី **សាយ ឈុំ**	ប្រុស	
២	ឯកឧត្តម **នៃ ម៉ៃណា**	ប្រុស	
៣	ឯកឧត្តម **ទេព ចន**	ប្រុស	
៤	ឯកឧត្តម **ស៊ឹម កា**	ប្រុស	
៥	ឯកឧត្តម **ជា ដេដ្ឋ**	ប្រុស	
៦	ឯកឧត្តម **អ៊ុក ប៊ុនឈឿន**	ប្រុស	
៧	ឯកឧត្តម **គង់ សារាជ**	ប្រុស	
៨	លោកជំទាវ **ទី ម៉ូរ៉ាស៊ី**	ស្រី	
៩	ឯកឧត្តម **ម៉ាន់ ឈឿន**	ប្រុស	
១០	ឯកឧត្តម **ឈិត គីមយាត**	ប្រុស	
១១	លោកជំទាវ **ពុំ ស៊ីថាន់**	ស្រី	
១២	លោកជំទាវ **ឈូក ឈឹម**	ស្រី	
១៣	ឯកឧត្តម **ហោ ម៉ូរ៉ា**	ប្រុស	
១៤	ឯកឧត្តម **ឆួន សាមិន**	ប្រុស	
១៥	ឯកឧត្តម **ឡាវ ម៉េងឃីន**	ប្រុស	
១៦	ឯកឧត្តម **ម៉ម ប៊ុនធាង**	ប្រុស	
១៧	ឯកឧត្តម **ឆាត់ ឈឿម**	ប្រុស	
១៨	ឯកឧត្តម **ហុង ឆូហាយ**	ប្រុស	
១៩	ឯកឧត្តម **សួន លង់**	ប្រុស	
២០	ឯកឧត្តម **អន ស៊ុំ**	ប្រុស	
២១	ឯកឧត្តម **អាំ សំអាត**	ប្រុស	
២២	ឯកឧត្តម **ចាន់ ណារ៉ែត**	ប្រុស	
២៣	ឯកឧត្តម **យឹម សេត**	ប្រុស	
២៤	ឯកឧត្តម **អ៊ុក គង់**	ប្រុស	
២៥	លោកជំទាវ **ជិន សុចីម**	ស្រី	
២៦	ឯកឧត្តម **កុក អាន**	ប្រុស	
២៧	ឯកឧត្តម **អ៊ុច ទី**	ប្រុស	
២៨	ឯកឧត្តម **ម៉ុច ឫទ្ធី**	ប្រុស	

២៩	ឯកឧត្តម **ពុធ ឌួច**	ប្រុស	
៣០	លោកជំទាវ **ហាន សំអាន**	ស្រី	
៣១	ឯកឧត្តម **ឈួន ឡេង**	ប្រុស	
៣២	ឯកឧត្តម **ជា សុន**	ប្រុស	
៣៣	ឯកឧត្តម **ឈួន សឿន**	ប្រុស	
៣៤	ឯកឧត្តម **ម៉ែន ស៊ីថាន់**	ប្រុស	
៣៥	ឯកឧត្តម **ទឹម ថន**	ប្រុស	
៣៦	លោកជំទាវ **ឡាក់ អូន**	ស្រី	
៣៧	ឯកឧត្តម **លី យ៉ុងថាត់**	ប្រុស	
៣៨	ឯកឧត្តម **ឡាយ អ៊ីពិសិទ្ធិ**	ប្រុស	
៣៩	ឯកឧត្តម **ជុំ វច**	ប្រុស	
៤០	ឯកឧត្តម **ថុច ចន់**	ប្រុស	
៤១	ឯកឧត្តម **ប៊ូ ថច**	ប្រុស	
៤២	ឯកឧត្តម **យ៉ង់ សែម**	ប្រុស	
៤៣	ឯកឧត្តម **ស៊ើយ កែវ**	ប្រុស	
៤៤	ឯកឧត្តម **ង៉ាន់ ឆុង**	ប្រុស	
៤៥	លោកជំទាវ **កែវ ម៉ាលី**	ស្រី	
៤៦	ឯកឧត្តម **ង៉ាន់ ម៉ាត់**	ប្រុស	

២- គណបក្ស សម រង្ស៊ី

ល.រ	គោត្តនាម-នាម	ភេទ	គណបក្ស
១	លោកជំទាវ **លី ឆារី**	ស្រី	
២	ឯកឧត្តម **ចេម គីមអ៊ាង**	ប្រុស	
៣	លោកជំទាវ **ថាក់ ឡានី**	ស្រី	
៤	ឯកឧត្តម **សួន ង៉ាន់ឡេង**	ប្រុស	
៥	លោកជំទាវ **ឡាយ ម៉ូនី**	ស្រី	
៦	ឯកឧត្តម **ហុង សុខហួរ**	ប្រុស	
៧	ឯកឧត្តម **សោ ចាន់ដេត**	ប្រុស	
៨	ឯកឧត្តម **ទាវ វណ្ណាល**	ប្រុស	
៩	ឯកឧត្តម **យឹម ឃុនឃឿន**	ប្រុស	
១០	ឯកឧត្តម **ឃូ ស៊ាងហេង**	ប្រុស	
១១	ឯកឧត្តម **សេង ម៉ារឌី**	ប្រុស	

៣- តែងតាំងដោយព្រះមហាក្សត្រ

ល.រ	គោត្តនាម-នាម	ភេទ	តំណាងព្រះមហាក្សត្រ
១	ឯកឧត្តម **អ៊ុំ ម៉ាឌូរីន**	ប្រុស	
២	ឯកឧត្តម **អៀវ បណ្ណាការ**	ប្រុស	


៤- ជ្រើសតាំងដោយរដ្ឋសភា

ល.រ	គោត្តនាម-នាម	ភេទ	តំណាងរដ្ឋសភា
១	ឯកឧត្តម **ខៀវ មុត**	ប្រុស	
២	ឯកឧត្តម **ប្រាក់ ចំរើន**	ប្រុស	

១០-តារាងប្រៀបធៀបចំនួនសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨) តាមប្រតិពគណបក្ស និងស្ថាប័ន


គណបក្សប្រជាជន	គណបក្សសម រង្ស៊ី	តំណាងព្រះមហាក្សត្ស	តំណាងរដ្ឋសភា
៤៦រូប	១១រូប	២រូប	២រូប

លទ្ធផលបោះឆ្នោតព្រឹទ្ធសភា




១១-តារាងប្រៀបធៀបចំនួនសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨) តាមភេទ

បុរស ៨១ រូប				ស្ត្រី ១០ រូប		
CPP	SRP	រដ្ឋសភា	រាជវាំង	CPP	SRP	រដ្ឋសភា
៤០រូប	៨រូប	១រូប	២រូប	៦រូប	៣រូប	១រូប



១២-តារាងប្រៀបធៀបចំនួនសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨) តាមលំដាប់អាយុ

អាយុ (៤០-៥០)	អាយុ (៥០-៦០)	អាយុ (៦០-៧០)	អាយុ (៧០-៨០)	អាយុ (៨០-៩០)
៥ រូប	២០ រូប	២៦ រូប	៨ រូប	២ រូប



១៣- សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៣



ឯកឧត្តម នៃ ម៉េណា
អនុប្រធានទី១ ព្រឹទ្ធសភា
សមាជិក



សម្តេចវិបុលសេនាភក្តី សាយ ឈុំ
ប្រធានព្រឹទ្ធសភា
ប្រធាន



ឯកឧត្តម ទេព ចន
អនុប្រធានទី២ ព្រឹទ្ធសភា
សមាជិក



ឯកឧត្តម ងាវ វណ្ណុល
ប្រធានគណៈកម្មការទី១
សមាជិក



ឯកឧត្តម ជា ដេដ្ឋ
ប្រធានគណៈកម្មការទី២
សមាជិក



ឯកឧត្តម ម៉ុង ឫទ្ធី
ប្រធានគណៈកម្មការទី៣
សមាជិក



ឯកឧត្តម ប៊ូ ថង
ប្រធានគណៈកម្មការទី៤
សមាជិក



លោកជំទាវ ទី ប៉ូស៊ី
ប្រធានគណៈកម្មការទី៥
សមាជិកា



ឯកឧត្តម អ៊ុក ប៊ុនឈឿន
ប្រធានគណៈកម្មការទី៦
សមាជិក



ឯកឧត្តម ម៉ាន់ ឈឿន
ប្រធានគណៈកម្មការទី៧
សមាជិក



លោកជំទាវ មាន សំអន
ប្រធានគណៈកម្មការទី៨
សមាជិកា



ឯកឧត្តម គង់ សារាជ
ប្រធានគណៈកម្មការទី៩
សមាជិក



ឯកឧត្តម ហុង សុខហួរ
ប្រធានគណៈកម្មការទី១០
សមាជិក

១៤- សមាសភាពថ្នាក់ដឹកនាំ និងសមាសភាពគណៈកម្មការនានា របស់ព្រឹទ្ធសភា នីតិកាលទី៣

ក. សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភា:

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	សម្តេចវិបុលសេនាតន្តី **សាយ ឈុំ**	SAMDECH VIBOL SENA PHEAKDEY SAY CHHUM	ប្រធានព្រឹទ្ធសភា
២	ឯកឧត្តម **នៃ ប៉ែណា**	H.E Mr. NEY PENA	អនុប្រធានទី១
៣	ឯកឧត្តម **ទេព ងន**	H.E Mr. TEP NGORN	អនុប្រធានទី២

ខ. សមាសភាពគណៈកម្មការនានា:

១- គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **ទាវ វណ្ណុល**	H.E Mr. TEAV VANNOL	ប្រធាន
២	ឯកឧត្តម **យ៉ង សែម**	H.E Mr. YANG SEM	អនុប្រធាន
៣	ឯកឧត្តម **ចេប ឈមអ៊ាង**	H.E Mr. CHEP KIM EANG	លេខាធិការ
៤	លោកជំទាវ **ឡាយ បូនី**	H.E Mrs. LAY BONY	សមាជិកា
៥	ឯកឧត្តម **អ៊ុក គង**	H.E Mr. OUK KONG	សមាជិក

២- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **ជា ជេដ្ឋ**	H.E Mr. CHEA CHETH	ប្រធាន
២	លោកជំទាវ **ឡាក់ អូន**	H.E Mrs. LAK AUN	អនុប្រធាន
៣	ឯកឧត្តម **ឈួន ឡេង**	H.E Mr. CHHUON LENG	លេខាធិការ
៤	ឯកឧត្តម **ស៊ឹម កា**	H.E Mr. SIM KA	សមាជិក
៥	លោកជំទាវ **កែវ ម៉ាលី**	H.E Mrs. KEO MALY	សមាជិកា

៣- គណៈកម្មការ ផែនការ ទន្និយោគ កសិកម្ម ធនធានទឹក ឧត្តុនិយម អភិវឌ្ឍន៍ជនបទ និង បរិស្ថាន

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **ម៉ុង ឫទ្ធី**	H.E Mr. MONG RETHTHY	ប្រធាន
២	ឯកឧត្តម **យូ សាំងហេង**	H.E Mr. YOU SEANG HENG	អនុប្រធាន
៣	ឯកឧត្តម **ចាន់ ណារ៉ែត**	H.E Mr. CHAN NARETH	លេខាធិការ
៤	ឯកឧត្តម **យឹម សេត**	H.E Mr. YIM SET	សមាជិក
៥	លោកជំទាវ **ថាក់ ឡានី**	H.E Mrs. THAK LANY	សមាជិកា

៤- គណៈកម្មការ មហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **ប៊ូ ថង**	H.E Mr. BOU THANG	ប្រធាន
២	ឯកឧត្តម **ឡាយ អ៊ីពិសិដ្ឋ**	H.E Mr. LAY YPISITH	អនុប្រធាន
៣	ឯកឧត្តម **អន សុំ**	H.E Mr. AN SUM	លេខាធិការ
៤	ឯកឧត្តម **សឿយ កែវ**	H.E Mr. SOEUY KEO	សមាជិក
៥	លោកជំទាវ **ជិន សុខឹម**	H.E. Mrs. CHIN SO NGIM	សមាជិកា

៥- គណៈកម្មការ កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	លោកជំទាវ **ទី បូរ៉ាស៊ី**	H.E. Mrs. TY BORASY	ប្រធាន
២	ឯកឧត្តម **ឈិត គឹមយាត**	H.E Mr. CHHIT KIMYEAT	អនុប្រធាន
៣	លោកជំទាវ **ឈូក ឈឹម**	H.E. Mrs. CHHOUK CHHIM	លេខាធិការ
៤	ឯកឧត្តម **ហុង ទូហាយ**	H.E Mr. HONG TOUHAY	សមាជិក
៥	ឯកឧត្តម **ឡាវ ម៉េងឃីន**	H.E Mr. LAU MING KAN	សមាជិក

៦- គណៈកម្មការ នីតិកម្ម និងយុត្តធម៌

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **អ៊ុក ប៊ុនឈឿន**	H.E Mr. OUK BOUNCHHOEUN	ប្រធាន
២	ឯកឧត្តម **ជា សុន**	H.E Mr. CHEA SON	អនុប្រធាន
៣	ឯកឧត្តម **ថុង ចន់**	H.E Mr. THONG CHON	លេខាធិការ
៤	ឯកឧត្តម **ហេង បូរ៉ា**	H.E Mr. HENG BORA	សមាជិក
៥	ឯកឧត្តម **ជុំ វង**	H.E Mr. CHUM VONG	សមាជិក

៧- គណៈកម្មការ អប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ ឥតិ្រសិល្បៈនិងទេសចរណ៍

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **ម៉ាន់ ឈឿន**	H.E Mr. MANN CHHOEURN	ប្រធាន
២	ឯកឧត្តម **សួន វ៉ាន់ឡេង**	H.E Mr. SUON VANLENG	អនុប្រធាន
៣	ឯកឧត្តម **អ៊ុង ទី**	H.E Mr. UNG TY	លេខាធិការ
៤	ឯកឧត្តម **ឆាត់ ឈឿម**	H.E Mr. CHHAT LOEUM	សមាជិក
៥	ឯកឧត្តម **យឹម ឃុនឃឿន**	H.E Mr. YIM KHUN KHOEUN	សមាជិក

៨- គណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	លោកជំទាវ **ម៉ាន សំអាន**	H.E.Mrs. MEAN SOM AN	ប្រធាន
២	លោកជំទាវ **ពុំ ស៊ីចាន់**	H.E Mrs. PUM SICHAN	អនុប្រធាន
៣	ឯកឧត្តម **អាំ សំអាត**	H.E Mr. AM SAM ATH	លេខាធិការ
៤	ឯកឧត្តម **នួន សាមិន**	H.E Mr. NUOUN SAMIN	សមាជិក
៥	លោកជំទាវ **លី នារី**	H.E Mrs. LY NEARY	សមាជិកា

៩- គណៈកម្មការ សាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **គង់ សារាជ**	H.E Mr. KONG SAREACH	ប្រធាន
២	ឯកឧត្តម **សួន លន់**	H.E Mr. SUON LOAN	អនុប្រធាន
៣	ឯកឧត្តម **ពុធ ខូវ**	H.E Mr. PUTH KHOV	លេខាធិការ
៤	ឯកឧត្តម **ទឹម ផន**	H.E Mr. TIM PHAN	សមាជិក
៥	ឯកឧត្តម **វ៉ាន់ វុធ**	H.E Mr. VANN VUTH	សមាជិក

១០- គណៈកម្មការ អន្តេវាសិក ជ្រោសរើសបុគ្គលិក និងប្រឆាំងអំពើពុករលួយ

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **ហុង សុខហួរ**	H.E Mr. HONG SOK HOUR	ប្រធាន
២	ឯកឧត្តម **ម៉ម ប៊ុនន៉ាង**	H.E Mr. MAM BOUNNEANG	អនុប្រធាន
៣	ឯកឧត្តម **សេង ម៉ារឌី**	H.E Mr. SENG MARDI	លេខាធិការ
៤	ឯកឧត្តម **ម៉ែន ស៊ីផាន់**	H.E Mr. MEN SIPHAN	សមាជិក
៥	ឯកឧត្តម **សោ ចាន់ដេត**	H.E Mr. SOR CHANDETH	សមាជិក

១៥- សមាជិកព្រឹទ្ធសភាក្រៅគណៈកម្មការ

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **អ៊ុំ ម៉ាណូរីន**	H.E Mr. OUM MANNORINE	សមាជិក
២	ឯកឧត្តម **អៀវ បណ្ណាការ**	H.E Mr. IEU PANNAKAR	សមាជិក
៣	ឯកឧត្តម **ខៀវ មុត**	H.E Mr. KHIEV MUTH	សមាជិក
៤	ឯកឧត្តម **ប្រាក់ ចំរើន**	H.E Mr. PRAK CHAM ROEUN	សមាជិក
៥	ឯកឧត្តម **កុក អាន**	H.E Mr. KOK AN	សមាជិក
៦	ឯកឧត្តម **លី យ៉ុងផាត់**	H.E Mr. LY YONGPHAT	សមាជិក
៧	ឯកឧត្តម **ឈួន សឿន**	H.E Mr. CHHUON SOEUN	សមាជិក
៨	ឯកឧត្តម **វ៉ាន់ ម៉ាត់**	H.E Mr. VANN MATH	សមាជិក

១៦- ភារកិច្ចរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា នីតិកាលទី៣ (២០១២-២០១៨)

- **ប្រធានព្រឹទ្ធសភា មានភារកិច្ចដូចតទៅ ៖**

ក-ធានាការប្រព្រឹត្តទៅនៃព្រឹទ្ធសភាឲ្យបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ។

ខ-ដឹកនាំអង្គប្រជុំនៃព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍។

គ-ធានាដឹកនាំការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងឥស្សរជនសម្រាប់មុខតំណែងផ្សេងៗ ដែលកំណត់ដោយច្បាប់។

ឃ-ទទួលអាញ្ញត្តិច្បាប់ និងសេចក្តីសម្រេចផ្សេងៗ ដែលព្រឹទ្ធសភាបានអនុម័ត។

ង-ចាត់ចែងបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងដែលបានទទួលទៅគណៈកម្មការ ដើម្បីពិនិត្យសិក្សា និងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភា។

ច-លើកជូនអង្គប្រជុំព្រឹទ្ធសភាសម្រេចអំពីការស្នើសុំចាត់ទុកជាការប្រញាប់។

ឆ-បើកអង្គប្រជុំ ផ្អាកពេលប្រជុំ ឬលើកពេលប្រជុំព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍។

ជ-ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍។

ឈ-ញ៉ាំងឲ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

ញ-រក្សាការពារសណ្តាប់ធ្នាប់ក្នុងព្រឹទ្ធសភា។

ដ-តំណាងព្រឹទ្ធសភាក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ រដ្ឋសភា ឬអាជ្ញាធរសាធារណៈ។

ឋ-ទាក់ទងជាមួយប្រធានរដ្ឋសភា ដើម្បីរៀបចំសមាជរដ្ឋសភា និងព្រឹទ្ធសភា ស្របតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា។

ឌ-ចេញសេចក្តីសម្រេចចាត់តាំងក្រុមសមាជិកព្រឹទ្ធសភាឲ្យទទួលបន្ទុកការងារផ្សេងៗក្រោយពីទទួលបានការឯកភាពពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។

ឍ-រ៉ាប់រងការងារអន្តរជាតិរបស់ព្រឹទ្ធសភា។

(យោង៖ ប្រការ ១១ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី៣)

- **អនុប្រធានទី ១ និងអនុប្រធានទី ២ ព្រឹទ្ធសភា មានភារកិច្ចដូចតទៅ ៖**

អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា ត្រូវជួយប្រធានព្រឹទ្ធសភា ដើម្បីសម្រេចភារកិច្ចទាំងឡាយដែលមានចែងក្នុងប្រការ ១១ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ព្រមទាំងកិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានព្រឹទ្ធសភា ។

(យោង៖ សេចក្តីសម្រេចលេខ: ០១៨/០៩១២/ពស/សរ ស្តីពីភារកិច្ចរបស់អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា នីតិកាលទី៣)។

អនុប្រធានទាំងពីរជួយធ្វើការប្រធាន។ ក្នុងករណីប្រធានព្រឹទ្ធសភាមានធុរៈមិនអាចបំពេញមុខ-ងារបាន ឬទទួលមុខងារជាប្រមុខរដ្ឋស្តីទី ឬទៅបំពេញបេសកកម្មឯបរទេស អនុប្រធានទី១ វ៉ាប់រងការ-ងារជំនួស ក្នុងឋានៈជាប្រធានស្តីទី ។

បើទាំងប្រធាន ទាំងអនុប្រធានទី១ ស្ថិតក្នុងករណីដូចខាងលើ អនុប្រធានទី២ វ៉ាប់រងការងារ ជំនួស ក្នុងឋានៈជាប្រធានស្តីទីរហូតដល់ប្រធាន ឬអនុប្រធានទី១ ចូលបំពេញការងារវិញ។

(យោង៖ប្រកា១២-បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី៣)

១៧. តួនាទី ភារកិច្ច និងសមត្ថកិច្ចគណៈកម្មការនានានៃព្រឹទ្ធសភា

១-តួនាទី ភារកិច្ច និងសមត្ថកិច្ចគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត

ប្រការ ១ :

គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត ហៅកាត់ថា «គណៈកម្មការទី១» និងសរសេរជាអក្សរកាត់ «គ.ស.ប.អ.ព»។

ប្រការ ២ :

គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត មានតួនាទីជាសេនាធិការឲ្យព្រឹទ្ធសភាក្នុងការបំពេញមុខងារតំណាង មុខងារនីតិកម្ម និងមុខងារត្រួតពិនិត្យ និងធានាប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងសមត្ថកិច្ចគណៈកម្មការ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធ-សភា។

ប្រការ ៣ :

គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត មានភារកិច្ច ដូចតទៅ ៖

ក-គាំទ្រ លើកស្ទួយ និងការពារសិទ្ធិជនគ្រប់រូបឱ្យមានសេចក្តីថ្លៃថ្នូរ និងមានសិទ្ធិស្មើគ្នា ដើម្បីជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងសង្គមជាតិ ក្នុងតំបន់ និងក្នុងសកលលោក។

ខ-តាមដានត្រួតពិនិត្យនូវការអនុវត្តសិទ្ធិមនុស្សនៅកម្ពុជា ឱ្យបានសមស្របទៅតាមរដ្ឋ-ធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងឯកសារ បទដ្ឋានអន្តរជាតិទាំងឡាយក្នុងវិស័យសិទ្ធិមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានចូលរួមទទួលស្គាល់។

គ-ពិនិត្យឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬការងារផ្សេងៗ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ជូន។

ឃ-ទំនាក់ទំនងជាមួយគណៈកម្មការនានារបស់រដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ន នានា ដើម្បីសិក្សាឈ្វេងយល់ជាមុនរាល់គំនិតផ្តួចផ្តើមសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ ឬបញ្ហាទាំងពួង ដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ។

ង-អញ្ជើញតំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នក ស្នើច្បាប់ ដែលជាម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដើម្បីចូលមកបំភ្លឺ នៅចំពោះមុខគណៈកម្មការ។

ច-ផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ ដើម្បីអនុវត្តបទប្បញ្ញត្តិសិទ្ធិមនុស្សនានាដែលមាន ចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងឯកសារសិទ្ធិមនុស្សអន្តរជាតិទាំងឡាយ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា។

ឆ-ទទួលពាក្យបណ្តឹងទូទៅពីបុគ្គល អ្នកតំណាងក្រុម អង្គការ ឬសមាគមនានា ។

ជ-ពិនិត្យពាក្យបណ្តឹង និងធ្វើការសម្របសម្រួល ដើម្បីស្វែងរកដំណោះស្រាយនៃពាក្យបណ្តឹងនោះដោយសហការជាមួយស្ថាប័ន ឬសមត្ថកិច្ចនានា ។

ឈ-ពាក្យបណ្តឹងទាំងឡាយណាដែលក្រសួង ឬស្ថាប័នមានសមត្ថកិច្ចដោះស្រាយរួចម្តងហើយ និងពាក្យបណ្តឹងទាំងឡាយណា ដែលតុលាការគ្រប់ជាន់ថ្នាក់បាន និងកំពុងដោះស្រាយនោះ គណៈកម្មការត្រូវតម្កល់ទុកមិនចាត់ការ ហើយត្រូវជូនដំណឹងអំពីពាក្យបណ្តឹងតម្កល់ទុកមិនចាត់ការនោះទៅដល់ដើមបណ្តឹង ដើម្បីជ្រាបវិញ ។

ញ-ចុះអង្កេត ស្រាវជ្រាវ និងប្រមូលព័ត៌មានលើពាក្យបណ្តឹងនៅមូលដ្ឋាននានា រួចធ្វើរបាយការណ៍ ស្តីពីលទ្ធផលនៃការស្រាវជ្រាវនោះជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា ឬលើកសំណូមពរជូនទៅស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយ ។

ត-ចុះបំពេញបេសកកម្មតាមក្រសួង ស្ថាប័ន និងភូមិភាគ ដើម្បីឈ្វេងយល់ការអនុវត្តច្បាប់ បញ្ហាទាំងពួង កម្មវិធីនយោបាយ គោលនយោបាយជាតិ និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងព្រឹទ្ធសភា និង/ឬលើកអនុសាសន៍ ឬអន្តរាគមន៍សុំឲ្យធ្វើការកែសម្រួល ឬដោះស្រាយបញ្ហាទាំងនោះ។

ថ-ផ្តួចផ្តើមគំនិតធ្វើសិក្ខាសាលា ឬសវនាការសាធារណៈជាមួយក្រសួង ស្ថាប័ន ឥស្សរជនជាតិ និងអន្តរជាតិ អ្នកជំនាញការ និងអង្គការសង្គមស៊ីវិល ដើម្បីប្រមូលព័ត៌មាន ឬឲ្យធ្វើបទបង្ហាញពីការងារទាក់ទងនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ។

ទ-ទំនាក់ទំនងជាមួយអង្គការជាតិ អង្គការអន្តរជាតិ វិស័យឯកជន និងវិស័យផ្សេងៗ ដើម្បីសិក្សាឈ្វេងយល់អំពីបញ្ហាទាំងពួង ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន និងស្វែងរកជំនួយថវិកា សម្ភារពីប្រភពទាំងនោះ សម្រាប់ដំណើរការផ្សព្វផ្សាយសិទ្ធិមនុស្សជូនដល់ប្រជាពលរដ្ឋ និងការអង្កេតនៅកម្ពុជាឲ្យមានប្រសិទ្ធភាព។

ធ-ពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយដៃគូអភិវឌ្ឍន៍ សភាបណ្តាប្រទេសនានាទាំងក្នុងតំបន់ និងសកលលោក តាមរយៈទស្សកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ក្នុងការឈ្វេងយល់លើការងារដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ក៏ដូចជាការងារសភា ជាពិសេសដើម្បីកៀរគរជំនួយសំរាប់អភិវឌ្ឍន៍ធនធានមនុស្ស និងព្រឹទ្ធសភា។

ន-បំពេញការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រគល់ជូន។

ប្រការ ៨ :

គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេតមានសមត្ថកិច្ចបំពេញមុខងារតំណាងឲ្យភូមិភាគ និងតំណាងឲ្យប្រជាជាតិខ្មែរទាំងមូល និងអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ក្រមសីលធម៌សមាជិកព្រឹទ្ធសភា លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីសម្រេចនានារបស់ព្រឹទ្ធសភា ។

ប្រការ ៨ :

គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត គណៈកម្មការនានានៃព្រឹទ្ធសភា ដែលពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

(ឃោង៖ សេចក្តីសម្រេចលេខ:០២០/០៩១២/ពស/ស.រ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីតួនាទីភារកិច្ច និងសមត្ថកិច្ច និងលេខ: ០៩២/០៩១៤/ពស/ស.រ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពគណៈកម្មការទី១ ព្រឹទ្ធសភា ដែលត្រូវបានកែសម្រួលឡើងវិញ)

សមាសភាពគណៈកម្មការទី១ ព្រឹទ្ធសភា



ឯកឧត្តម ទាវ ឥណ្ណាល

ប្រធាន



ឯកឧត្តម យ៉ង់ សែម

អនុប្រធាន



ឯកឧត្តម ចេម ឥមអ៊ាង

លេខាធិការ



លោកជំទាវ ឡាយ បូនី

សមាជិកា



ឯកឧត្តម អ៊ុក គង់

សមាជិក

សមាសភាពលេខាធិការដ្ឋានអមគណៈកម្មការទី១



លោក **កេត ជិន្ឌ័ន**

ប្រធាន

០១២ ៧៧៧ ២៤៦



កញ្ញា **អ៊ុក ចិន្តា**

អនុប្រធាន

០១២ ៤៦៤ ៩១០

២-តួនាទី តារកិច្ច និងសមត្ថកិច្ចគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

ប្រការ ១ :

គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា ហៅកាត់ថា «គណៈកម្មការទី២» និងសរសេរជាអក្សរកាត់ «គ.ស.ហ.ធ.ស»។

ប្រការ ២ :

គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មមានតួនាទីជាសេនាធិការក្នុងការបំពេញមុខងារតំណាង មុខងារនីតិកម្ម និងមុខងារត្រួតពិនិត្យ ព្រមទាំងធានាប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា ។

ប្រការ ៣ : **គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម មានភារកិច្ចដូចតទៅ ៖**

- ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងបញ្ហាទាំងពួង ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ជូន
- ទំនាក់ទំនងជាមួយគណៈកម្មការនានារបស់ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីឈ្វេងយល់ជាមុននូវគំនិតផ្តួចផ្តើម និងការសម្រេចលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- អញ្ជើញតំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នកស្នើច្បាប់ដែលជាម្ចាស់សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង មកបំភ្លឺចំពោះមុខគណៈកម្មការ
- អញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាង អង្គការសង្គមស៊ីវិល ចូលរួមផ្តល់យោបល់លើបញ្ហាផ្សេងៗ
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ សំណូមពរ ឬចំណាប់អារម្មណ៍ផ្សេងៗ បើមាន
- សិក្សាស្រាវជ្រាវ និងប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីរាយការណ៍ ឬលើកយោបល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ឬផ្តល់ជាអនុសាសន៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ
- ធ្វើរបាយការណ៍ អំពីព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយធ្វើការវិភាគ និងវាយតម្លៃ បន្ទាប់មករាយការណ៍អំពីលទ្ធផលទាំងនោះជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា
- ផ្តួចផ្តើមគំនិតរៀបចំកិច្ចពិគ្រោះយោបល់ សិក្ខាសាលា វេទិកាសាធារណៈ បេសកកម្មក្នុង និងក្រៅប្រទេសរបស់គណៈកម្មការ បន្ទាប់មកធ្វើរបាយការណ៍ជូនគណៈកម្មាធិការ

អចិន្ត្រៃយ៍ និងព្រឹទ្ធសភា

- ចុះបំពេញបេសកកម្មស្វែងរកព័ត៌មានតាមក្រសួង ស្ថាប័ន និងតាមដានការអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការនៅថ្នាក់ក្រោមជាតិ និងភូមិភាគទាំង៨ បន្ទាប់មកធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍និងអង្គព្រឹទ្ធសភា និង/ឬលើកជាអនុសាសន៍ ឬធ្វើអន្តរាគមន៍ទៅក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការសម្របសម្រួល និង/ឬដោះស្រាយ
- ទំនាក់ទំនងជាមួយអង្គការជាតិ-អន្តរជាតិ និងស្ថានទូតអន្តរជាតិនានា ដើម្បីសិក្សាឈ្វេងយល់បញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- ពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយដៃគូអភិវឌ្ឍន៍ សភាប្រទេសនានាក្នុងតំបន់ និងសកលលោក តាមរយៈទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងសិក្សាឈ្វេងយល់អំពីការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- កសាងគោលការណ៍ បទដ្ឋានគតិយុត្ត និងនីតិវិធីសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ដែលទាក់ទងនឹងថវិកាស្វយ័តរបស់ព្រឹទ្ធសភា ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍សម្រេច
- លើកផែនការថវិកា ត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ថវិកាស្វយ័តរបស់ព្រឹទ្ធសភា ព្រមទាំងសិក្សាស្រាវជ្រាវ និងតាមដានរាល់កិច្ចការដែលទាក់ទងនឹងសវនកម្មផ្ទៃក្នុងរបស់ព្រឹទ្ធសភា
- គ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការហិរញ្ញវត្ថុរបស់គណៈកម្មការនានានៃព្រឹទ្ធសភា និងអង្គភាពពាក់ព័ន្ធ
- ពិនិត្យ និងផ្តល់យោបល់រាល់សំណើសុំថវិកា ឬតម្រូវការផ្សេងៗជាយថាហេតុរបស់ព្រឹទ្ធសភា សំណូមពរផ្ទាល់របស់សមាជិក សមាជិកានៃព្រឹទ្ធសភា និងអង្គភាពពាក់ព័ន្ធមុននឹងបញ្ជូនសំណើ ឬសំណូមពរទៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បំពេញការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ជូន។

ប្រការ ៤ :

គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម មានសមត្ថកិច្ចប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទដ្ឋានគតិយុត្តនានាជាធរមាន និងសេចក្តីសម្រេចនេះ ។

ប្រការ ៥ :

គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម គណៈកម្មការនានារបស់ព្រឹទ្ធសភាដែលមានការពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

(យោង៖ សេចក្តីសម្រេចលេខ: ០២១/០៩១២/ពស/ស.រ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីតួនាទីភារកិច្ច និងសមត្ថកិច្ច និងលេខ: ០០២/០៣១២/ពស/ស.រ.គ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ លេខ:០២២/០២១៣/ពស/ស.រ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ស្តីពីការទទួលស្គាល់សមាសភាពគណៈកម្មការទី២ ព្រឹទ្ធសភា)

សមាសភាពគណៈកម្មការទី២ ព្រឹទ្ធសភា



ឯកឧត្តម ជា ជេដ្ឋ

ប្រធាន



លោកជំទាវ ឡាក់ អូន

អនុប្រធាន



ឯកឧត្តម ឈួន ឡេង

លេខាធិការ



ឯកឧត្តម ស៊ឹម កា

សមាជិក



លោកជំទាវ កែវ ម៉ាលី

សមាជិកា

សមាសភាពលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មការទី២



លោក **ហ៊ួយ ង៉ាន់ឌី**

ប្រធាន

០១២ ៨៣២ ៣៨២



លោកស្រី **ជេត កណ្ណិកា**

អនុប្រធាន

០១២ ៧៧៥ ៩២២



លោក **កែវ ពិសិដ្ឋវិទូ**

អនុប្រធាន

០១២ ៥៥៩ ៤០០



លោកស្រី **ចាន់ ស្រីចា**

អនុប្រធាន

០១៧ ៣៧ ៦៨ ៦៨

៣-តួនាទី ភារកិច្ច និងសមត្ថកិច្ចគណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន

ប្រការ១ :

គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ហៅកាត់ថា «គណៈកម្មការទី៣» សរសេរជាអក្សរកាត់ «គ.ផ.វ.ក.ធ.ឧ.អ.ប »។

ប្រការ២ :

គ.ផ.វ.ក.ធ.ឧ.អ.ប. មានលេខាធិការដ្ឋានអមជាសេនាធិការ ដែលទទួលបន្ទុកការងារ រដ្ឋបាល បច្ចេកទេស ស្រាវជ្រាវ ឯកសារគតិយុត្ត និងវិភាគព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ និងការងារពាក់ព័ន្ធទៅជាមួយនឹងអគ្គលេខាធិការដ្ឋានព្រឹទ្ធ-សភា។ លេខាធិការដ្ឋានអមគណៈកម្មការ មានរចនាសម្ព័ន្ធជាខ្សែបណ្តោយនៃអគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា។

ប្រការ៣ :

គ.ផ.វ.ក.ធ.ឧ.អ.ប. មានតួនាទីជាសេនាធិការព្រឹទ្ធសភាក្នុងការបំពេញមុខងារតំណាង មុខងារនីតិកម្ម និងមុខងារត្រួតពិនិត្យ និងធានាទៅដល់ការប្រមូលព័ត៌មាន ដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍និងព្រឹទ្ធសភា។

ប្រការ ៤ :

គ.ផ.វ.ក.ធ.ឧ.អ.ប. មានភារកិច្ចត្រូវ :

១-ពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬការងារផ្សេងៗទៀតដែលគណៈកម្មាធិការអចិន្ត្រៃយ៍សម្រេចប្រគល់ឲ្យ។

២-ផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ។

៣-ទាក់ទងនិងសហប្រតិបត្តិការជាមួយគណៈកម្មការរបស់រដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីសិក្សាឈ្វេងយល់ជាមុនរាល់គំនិតផ្តួចផ្តើម និងការសម្រេចលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ។

៤-អញ្ជើញសមាជិករដ្ឋសភា ឬតំណាងរាជរដ្ឋាភិបាល ឬជាម្ចាស់នៃសេចក្តីស្នើ ដែលសុំកែសម្រួល ឬអ្នកស្នើច្បាប់ដែលជាម្ចាស់នៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដើម្បីចូលមកបំភ្លឺនៅចំពោះមុខគណៈកម្មការ។

៥-អញ្ជើញតំណាងក្រសួងពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាងសង្គមស៊ីវិល ដើម្បីចូលរួមផ្តល់យោបល់អំពីបញ្ហាផ្សេងៗ។

៦-ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការពិនិត្យ និងកំណែតម្រូវនៅលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គ

ព្រឹទ្ធសភាដោយភ្ជាប់ជាមួយនូវអនុសាសន៍ ឬសំណូមពរ ឬចំណាប់អារម្មណ៍ផ្សេងៗ ប្រសិនណាបើពិនិត្យឃើញ។

៧-សិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ តាមរយៈសេចក្តីរាយការណ៍របស់ក្រសួងពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិ ក៏ដូចជាតាមរយៈសារព័ត៌មានជាតិ និងអន្តរជាតិនានា។

៨-អនុវត្តមុខងារតាមវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយធ្វើការត្រួតពិនិត្យ វិភាគវាយតម្លៃ និងសន្និដ្ឋាននៅលើកិច្ចការនានា បន្ទាប់មករៀបចំជាសេចក្តីរាយការណ៍ពិស្តារជូនគណៈកម្មាធិការអចិន្ត្រៃយ៍និងអង្គព្រឹទ្ធសភា។

៩-ផ្តួចផ្តើមគំនិតកសាងគម្រោងផែនការអនុវត្តប្រចាំឆ្នាំ ដូចជារៀបចំធ្វើសិក្ខាសាលាបេសកកម្មក្នុងប្រទេស និងក្រៅប្រទេសរបស់គណៈកម្មការ។

១០-ទាក់ទងជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងស្ថានទូតនានា ដើម្បីសិក្សាឈ្វេងយល់អំពីបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ និងព្រឹទ្ធសភា។

១១-ធ្វើការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយសភាបណ្តាប្រទេសនៅក្នុងតំបន់និងសកលលោក និងដៃគូអភិវឌ្ឍន៍អន្តរជាតិនានា តាមរយៈទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងឈ្វេងយល់បន្ថែមអំពីការអភិវឌ្ឍដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ជាពិសេសដើម្បីកៀរគរជំនួយសម្រាប់អភិវឌ្ឍព្រឹទ្ធសភា និងអភិវឌ្ឍន៍ធនធានមនុស្ស។

១២-ប្រជុំបូកសរុបលទ្ធផលការងារ ពិនិត្យរបាយការណ៍ចំណូល ចំណាយ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ របស់គណៈកម្មការ។

១៣-ធ្វើការងារចាំបាច់ផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍សម្រេចប្រគល់ឲ្យ។

ប្រការ៥ :

គ.ផ.វ.ក.ធ.ឧ.អ.ប. បំពេញការងារទៅតាមវិស័យជាសមត្ថកិច្ចដោយចុះបំពេញបេសកកម្មស្វែងរកព័ត៌មាននៅតាមក្រសួងពាក់ព័ន្ធ តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ចរដ្ឋបាល ថ្នាក់ក្រោមជាតិនៅក្នុងភូមិភាគទាំង៨ បន្ទាប់មកធ្វើសេចក្តីរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និង/ឬក៏ផ្តល់ជាអនុសាសន៍ ឬក៏រៀបចំបែបបទអន្តរាគមន៍ទៅក្រសួងពាក់ព័ន្ធ ដើម្បីធ្វើការបំភ្លឺត្រឡប់ ជាលាយលក្ខណ៍អក្សរ។

ប្រការ៦ :

កូរ៉ុមសម្រាប់ប្រជុំគណៈកម្មការ ត្រូវមានលើសពីពាក់កណ្តាល នៃសមាជិកគណៈកម្មការទាំងមូល ហើយរាល់ការសម្រេចរបស់គណៈកម្មការ ត្រូវអនុម័តដោយសំឡេងភាគច្រើនដាច់ខាត។

ប្រការ៧ :

គ.ផ.វ.ក.ធ.ឧ.អ.ប. ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទដ្ឋានគតិយុត្តនានាជាធរមាន និងសេចក្តីសម្រេចនេះ។

ប្រការ៨ :

ប្រធានគណៈកម្មការទី៣ ប្រធានគណៈកម្មការនានាដែលពាក់ព័ន្ធ អគ្គលេខាធិការព្រឹទ្ធសភាត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពតាមការកិច្ចរៀងៗខ្លួន។

ប្រការ៩ :

សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១០ :

សេចក្តីសម្រេចនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

(យោង៖ សេចក្តីសម្រេចលេខៈ ០២២/០៩១២/ពស/ស.រ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីតួនាទីភារកិច្ច និងសមត្ថកិច្ច និងលេខៈ០៩៣/០៩១៤/ពស/ស.រ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពគណៈកម្មការទី៣ ដែលត្រូវបានកែសម្រួលឡើងវិញ)

សមាសភាពគណៈកម្មការទី៣ ព្រឹទ្ធសភា



ឯកឧត្តម ម៉ុង ឫទ្ធី

ប្រធាន



ឯកឧត្តម យូ ស៊ាងហោង

អនុប្រធាន



ឯកឧត្តម ចាន់ ណារ៉ែត

លេខាធិការ



ឯកឧត្តម យឹម សេត

សមាជិក



លោកជំទាវ ថាក់ ឡានី

សមាជិកា

សមាសភាពលេខាធិការដ្ឋានអមគណៈកម្មការទី៣



លោក **ហ្សេង ជាវី**

ប្រធាន

០១១ ៨៧៥ ៥៧៥



លោកស្រី **ឈឹម ច័ន្ទវត្ត**

អនុប្រធាន

០៨៩ ៥៥៩ ៧៣៣

៤-តួនាទី តារកិច្ច និងសមត្ថកិច្ចគណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ

ប្រការ១ :

គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ ហៅកាត់ថា «គណៈកម្មការទី៤» សរសេរជាអក្សរកាត់ «គ.៤»។

ប្រការ២ :

គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ មានតួនាទីធ្វើជាសេនាធិការក្នុងការបំពេញមុខងារនីតិកម្ម មុខងារត្រួតពិនិត្យ និងមុខងារតំណាង និងប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងសមត្ថកិច្ចគណៈកម្មការជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា។

ប្រការ៣ :

គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ មានភារកិច្ចដូចតទៅ ៖

-ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ជូន។

-ផ្តួចផ្តើមគំនិតធ្វើច្បាប់ ឬស្នើសុំធ្វើវិសោធនកម្មច្បាប់ ឬបញ្ហាទាំងពួងដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ។

-ទំនាក់ទំនងជាមួយគណៈកម្មការនានារបស់រដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីសិក្សាឈ្វេងយល់ជាមុនរាល់គំនិតផ្តួចផ្តើម និងការសម្រេចលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ។

-អញ្ជើញតំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នកស្នើច្បាប់ ដែលជាម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង មកបំភ្លឺជូនគណៈកម្មការ។

-អញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាង សង្គមស៊ីវិល ចូលរួមឲ្យយោបល់លើបញ្ហាផ្សេងៗ។

-ធ្វើរបាយការណ៍អំពីលទ្ធផល នៃការពិនិត្យលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងអង្គព្រឹទ្ធសភា ដោយភ្ជាប់ជាមួយនូវអនុសាសន៍ ឬជាសំណូមពរ ឬចំណាប់អារម្មណ៍ផ្សេងៗ។

-សិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មាន ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ តាមរយៈរបាយការណ៍របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអង្គការអន្តរជាតិ សារព័ត៌មានជាតិ និងអន្តរជាតិ។

-បំពេញមុខងារតាមវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយធ្វើការត្រួតពិនិត្យ វិភាគ វាយតម្លៃ និងសន្និដ្ឋាននៅលើកិច្ចការនានា បន្ទាប់មករៀបចំជារបាយការណ៍ពិស្តារជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា។

-ផ្តួចផ្តើមគំនិតរៀបចំកិច្ចពិគ្រោះយោបល់ សិក្ខាសាលា បេសកកម្មក្នុង និងក្រៅប្រទេសរបស់គណៈកម្មការ។

-ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិនានា សភាបណ្តាប្រទេសក្នុងតំបន់ និងសកលលោក តាមរយៈទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងសិក្ខាឈ្វេងយល់បន្ថែមអំពីការអភិវឌ្ឍដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ពិសេសដើម្បីកៀរគរជំនួយសម្រាប់អភិវឌ្ឍន៍ព្រឹទ្ធសភា និងអភិវឌ្ឍន៍ធនធានមនុស្ស ។

-ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តនានាជាធរមាន និងសេចក្តីសម្រេចនេះ ។

-បំពេញការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ជូន ។

ប្រការ ៨ :

គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ បំពេញការងារទៅតាមវិស័យជាសមត្ថកិច្ច ដោយចុះបេសកកម្មស្វែងរកព័ត៌មាននៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅមូលដ្ឋាននិងភូមិភាគទាំង៨ បន្ទាប់មកធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និង/ឬលើកជាអនុសាសន៍ ឬអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការដោះស្រាយ។

ប្រការ ៩ :

គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ គណៈកម្មការនានារបស់ព្រឹទ្ធសភាដែលមានការពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

(យោង៖ សេចក្តីសម្រេចលេខ: ០២៣/០៩១២/ពស/ស.រ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីតួនាទីភារកិច្ច និងសមត្ថកិច្ច និងលេខ:០០៤/០៣១២/ពស/ស.រ.គ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការទទួលស្គាល់សមាសភាពគណៈកម្មការទី៤ ព្រឹទ្ធសភា)

សមាសភាពគណៈកម្មការទី៤ ព្រឹទ្ធសភា



ឯកឧត្តម ប៊ូ ថង

ប្រធាន



ឯកឧត្តម ឡាយ អ៊ីពិសិទ្ធិ

អនុប្រធាន



ឯកឧត្តម អន ស៊ុំ

លេខាធិការ



ឯកឧត្តម ស៊ើយ កែវ

សមាជិក



លោកជំទាវ ជិន សុចិម

សមាជិកា

សមាសភាពលេខាធិការដ្ឋានអមគណៈកម្មការទី៤



លោក **ជា គីមលីន**

ប្រធាន

០៩៧ ៨៨ ៣០៣០៧



កញ្ញា **កែវ សុជាតា**

អនុប្រធាន

០៧៧ ៧៣ ៧៣ ១៦

៥-តួនាទី តារកិច្ច និងសមត្ថកិច្ចគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

ប្រការ ១ :

គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ហៅកាត់ថា «គណៈកម្មការទី៥» និងសរសេរជាអក្សរកាត់ «គ.ប.ស.ឃ.ព »។

ប្រការ ២ :

គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន មានតួនាទីជាសេនាធិការក្នុងការបំពេញមុខងារតំណាង មុខងារនីតិកម្ម និងមុខងារត្រួតពិនិត្យ ព្រមទាំងធានាក្នុងការប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា។

ប្រការ ៣ :

គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន មានភារកិច្ចដូចតទៅ :

- ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងបញ្ហាទាំងពួងដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រគល់ជូន
- ទាក់ទងជាមួយគណៈកម្មការនានារបស់ព្រឹទ្ធសភា និងរដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីឈ្វេងយល់ជាមុននូវគំនិតផ្តួចផ្តើម និងការសម្រេចលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- អញ្ជើញតំណាងក្រសួងពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាងសង្គមស៊ីវិលចូលរួមឲ្យយោបល់លើបញ្ហាផ្សេងៗ
- ធ្វើសេចក្តីរាយការណ៍ អំពីលទ្ធផលនៃការពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ សំណូមពរ ឬចំណាប់អារម្មណ៍ផ្សេងៗ ប្រសិនបើមាន
- ជួយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ក្នុងការតាមដាន និងសម្របសម្រួលការបង្កើតក្រុមមិត្តភាព ឬក្រុមទទួលបន្ទុកការងារអន្តរជាតិរបស់ព្រឹទ្ធសភា ជាមួយអង្គការ សភាតំបន់ និងអន្តរជាតិផ្សេងៗទៀត
- សិក្សាស្រាវជ្រាវ និងប្រមូលផ្តុំព័ត៌មានផ្សេងៗទាំងក្នុង និងក្រៅប្រទេសដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីរាយការណ៍ ឬលើកយោបល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ផ្តល់អនុសាសន៍ជូនក្រសួងស្ថាប័ន ពាក់ព័ន្ធ
- ផ្តួចផ្តើមគំនិតរៀបចំសិក្ខាសាលា បេសកកម្មក្នុង និងក្រៅប្រទេសរបស់គណៈកម្មការ

- ពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយដៃគូអភិវឌ្ឍន៍សភាប្រទេសនានា ក្នុងតំបន់ និងសកលលោក តាមរយៈទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងឈ្វេងយល់ពីការអភិវឌ្ឍនានាពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីទទួលបានការគាំទ្រ និងជំនួយឧបត្ថម្ភ ទាំងស្មារតី បច្ចេកទេស ថវិកា និងសម្ភារ
- បំពេញការងារផ្សេងៗទៀតដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រគល់ជូន។

ប្រការ ៨ :

គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន មានសមត្ថកិច្ចប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទដ្ឋានគតិយុត្តនានាជាធរមាន និងសេចក្តីសម្រេចនេះ។

ប្រការ ៩ :

គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន គណៈកម្មការនានារបស់ព្រឹទ្ធសភាដែលមានការពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

(ឃោងៈ សេចក្តីសម្រេចលេខៈ ០២៤/០៩១២/ពស/ស.រ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីតួនាទីភារកិច្ច និងសមត្ថកិច្ច និងលេខៈ០០៥/០៣១២/ពស/ស.រ.គ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការទទួលស្គាល់សមាសភាពគណៈកម្មការទី៥ ព្រឹទ្ធសភា)

សមាសភាពគណៈកម្មការទី៥ ព្រឹទ្ធសភា



លោកជំទាវ ទី ប៉ូស៊ី

ប្រធាន



ឯកឧត្តម ឈិត គមយាគ

អនុប្រធាន



លោកជំទាវ ឈូក ឈីម

លេខាធិការ



ឯកឧត្តម ហុង ឡុហាយ

សមាជិក



ឯកឧត្តម ឡាវ ម៉េងឃីន

សមាជិក

សមាសភាពលេខាធិការដ្ឋានអមគណៈកម្មការទី៥



លោកស្រី**ជន ឥណ្ណារីឥណ្ណា**

អនុប្រធាន

០១៦ ៧៦១ ៦០៩



លោក **សាន សុខុម**

ប្រធាន

០១២ ៦០៤ ៣៣៧



លោក **សុខ សុវណ្ណាភ័**

អនុប្រធាន

០៧៧ ៥១ ៦១ ៥១

៦-តួនាទី តារកិច្ច និងសមត្ថកិច្ចគណៈកម្មការនីតិកម្ម និងយុត្តិធម៌

ប្រការ ១ :

គណៈកម្មការនីតិកម្ម និងយុត្តិធម៌ ហៅកាត់ថា «**គណៈកម្មការទី៦**» និងសរសេរជាអក្សរកាត់ថា «គ.ន.ក.យ» ជាអង្គការចាត់តាំងចំណុះព្រឹទ្ធសភា។

ប្រការ ២ :

គណៈកម្មការនីតិកម្ម និងយុត្តិធម៌ធ្វើជាសេនាធិការ ក្នុងការបំពេញមុខងារតំណាងមុខងារនីតិកម្ម និងមុខងារត្រួតពិនិត្យ និងធានាប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងសមត្ថកិច្ចគណៈកម្មការ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងព្រឹទ្ធសភា។

ប្រការ ៣ :

គណៈកម្មការនីតិកម្ម និងយុត្តិធម៌ មានភារកិច្ចដូចតទៅ :

ផ្តួចផ្តើមគំនិតធ្វើច្បាប់ ធ្វើវិសោធនកម្មច្បាប់ និងទទួលពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ សេចក្តីព្រាងច្បាប់ និងបញ្ហាទាំងពួងដែលពាក់ព័ន្ធនឹងសមត្ថកិច្ចគណៈកម្មការ។

ផ្តួចផ្តើមគំនិតធ្វើសិក្ខាសាលា ឬធ្វើសវនាការសាធារណៈជាមួយក្រសួងស្ថាប័ន ឥស្សរជនជាតិ និងអន្តជាតិ អ្នកជំនាញការ និងសង្គមស៊ីវិល ដើម្បីប្រមូលព័ត៌មាន ឬឲ្យធ្វើបទបង្ហាញពីការងារអ្វីមួយដែលជាប្រយោជន៍ដល់គណៈកម្មការ។

អញ្ជើញអ្នកធ្វើសេចក្តីព្រាងច្បាប់ ឬអ្នកធ្វើសេចក្តីស្នើច្បាប់ ឬអ្នកស្នើសុំកែសម្រួលសេចក្តីព្រាងច្បាប់ ឬអ្នកធ្វើសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង មកបំភ្លឺចំពោះមុខគណៈកម្មការ។

ចុះបេសកកម្មតាមក្រសួង ស្ថាប័ន និងភូមិភាគ ដើម្បីឈ្វេងយល់អំពីការ អនុវត្តច្បាប់ ឬបញ្ហាទាំងពួង កម្មវិធីនយោបាយ គោលនយោបាយជាតិ នឹងធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងព្រឹទ្ធសភា និង/ឬលើកអនុសាសន៍ ឬធ្វើអន្តរាគមន៍សុំឲ្យធ្វើការកែសម្រួល ឬដោះស្រាយបញ្ហាទាំងនេះ។

ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយដៃគូអភិវឌ្ឍន៍សភាបណ្តាប្រទេសក្នុងតំបន់ និងសកលោក តាមរយៈទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងកៀរគរជំនួយសម្រាប់ការអភិវឌ្ឍព្រឹទ្ធសភា និងធនធានមនុស្ស។

បំពេញការងារផ្សេងៗទៀតដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងព្រឹទ្ធសភាប្រគល់ជូន។

ប្រការ ៤ :

គណៈកម្មការនីតិកម្ម និងយុត្តិធម៌ មានសមត្ថកិច្ចបំពេញមុខងារតំណាងឲ្យភូមិភាគ និងតំណាងឲ្យប្រជាជាតិខ្មែរទាំងមូល និងអនុវត្តន៍តាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ក្រមសីលធម៌សមាជិកព្រឹទ្ធសភា លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីសម្រេចនានារបស់ព្រឹទ្ធសភា។

ប្រការ ៤ :

គណៈកម្មការនីតិកម្ម និងយុត្តិធម៌ គណៈកម្មការនានាដែលពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

(យោង៖ សេចក្តីសម្រេចលេខ: ០២៥/០៩១២/ពស/ស.រ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីតួនាទីភារកិច្ច និងសមត្ថកិច្ច និងលេខ:០៩៤/០៩១៤/ពស/ស.រ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពគណៈកម្មការទី៦ ព្រឹទ្ធសភា ដែលត្រូវបានកែសម្រួលឡើងវិញ)

សមាសភាពគណៈកម្មការទី៦ ព្រឹទ្ធសភា



ឯកឧត្តម អ៊ុក ប៊ុនឈឿន

ប្រធាន



ឯកឧត្តម ជា សុន

អនុប្រធាន



ឯកឧត្តម ថុច ចន់

លេខាធិការ



ឯកឧត្តម ហោ ប៉ូ

សមាជិក



ឯកឧត្តម ជុំ វាច

សមាជិក

សមាសភាពលេខាធិការដ្ឋានអមគណៈកម្មការទី៦



លោក **អ៊ុក រិទ្ធី**

អនុប្រធាន

០១៣ ៩៣៣ ៣៩៦



លោក **នៃ នីន**

ប្រធាន

០១៦ ២២២ ៣៣៧



លោកស្រី **ជឹ គេង**

អនុប្រធាន

០១៦ ៨៦៥ ៥០៥

៧-តួនាទី តារកិច្ច និងសមត្ថកិច្ចគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍

ប្រការ១ :

គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ហៅកាត់ថា «គណៈកម្មការទី៧» និងសរសេរជាអក្សរកាត់ «គ.អ.ធ.វ.ទ» ។

ប្រការ២ :

គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ មានតួនាទីជាសេនាធិការ ក្នុងការបំពេញមុខងារតំណាង មុខងារនីតិកម្ម មុខងារត្រួតពិនិត្យ និងធានាប្រមូលព័ត៌មាន ដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា។

ប្រការ៣ :

គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ មានភារកិច្ចដូចតទៅ :

- ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ជូន
- ទំនាក់ទំនងជាមួយគណៈកម្មការនានារបស់រដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីស្វែងយល់ជាមុននូវរាល់គំនិតផ្តួចផ្តើម និងការសម្រេចលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- អញ្ជើញតំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នកស្នើច្បាប់ ដែលជាម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬ បញ្ហាទាំងពួងមកបំភ្លឺចំពោះមុខគណៈកម្មការ
- អញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាងសង្គមស៊ីវិល ចូលរួមឲ្យយោបល់លើបញ្ហាផ្សេងៗ
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ សំណូមពរ ឬចំណាប់អារម្មណ៍ផ្សេងៗ ប្រសិនបើមាន
- សិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ តាមរយៈរបាយការណ៍របស់ក្រសួងពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិ ក៏ដូចជាតាមរយៈសារព័ត៌មានជាតិ អន្តរជាតិ និងប្រព័ន្ធអ៊ីនធើណេត

- ធ្វើរបាយការណ៍តាមវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយធ្វើការវិភាគ វាយតម្លៃ និងសន្និដ្ឋានបន្ទាប់មករាយការណ៍អំពីលទ្ធផលទាំងនោះជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា
- ផ្តួចផ្តើមគំនិតរៀបចំ សិក្ខាសាលា បេសកកម្មក្នុង និងក្រៅប្រទេសរបស់គណៈកម្មការ
- ចុះបំពេញបេសកកម្មស្វែងរកព័ត៌មាន តាមក្រសួងពាក់ព័ន្ធ និងតាមដានត្រួតពិនិត្យការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការនៅមូលដ្ឋាន និងភូមិភាគទាំង៨ បន្ទាប់មកធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និង/ឬលើកជាអនុសាសន៍ ឬអន្តរាគមន៍ទៅក្រសួងពាក់ព័ន្ធដើម្បីធ្វើការដោះស្រាយ
- ទំនាក់ទំនងជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងស្ថានទូតអន្តរជាតិនានា ដើម្បីឈ្វេងយល់នូវបញ្ហាទាំងពួង ដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ និងព្រឹទ្ធសភា
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយដៃគូអភិវឌ្ឍន៍នានា សភាបណ្តាប្រទេសក្នុងតំបន់ និងសកលលោក តាមរយៈទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងឈ្វេងយល់អំពីការអភិវឌ្ឍន៍ពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ជាពិសេសដើម្បីកៀរគរជំនួយសំរាប់អភិវឌ្ឍធនធានមនុស្ស និងព្រឹទ្ធសភា
- បំពេញការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រគល់ជូន។

ប្រការ៧ :

គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ មានសមត្ថកិច្ចប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទដ្ឋានគតិយុត្តិធរមានផ្សេងៗទៀត និងសេចក្តីសម្រេចនេះ។

ប្រការ៨ :

គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ គណៈកម្មការនានារបស់ព្រឹទ្ធសភាដែលពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

(យោង៖ សេចក្តីសម្រេចលេខ: ០២៦/០៩១២/ពស/ស.រ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីតួនាទីភារកិច្ច និងសមត្ថកិច្ច និងលេខ:០៩៥/០៩១៤/ពស/ស.រ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពគណៈកម្មការទី៧ ព្រឹទ្ធសភា ដែលត្រូវបានកែសម្រួលឡើងវិញ)

សមាសភាពគណៈកម្មការទី៧ ព្រឹទ្ធសភា



ឯកឧត្តម ម៉ាន់ ឈឿន

ប្រធាន



ឯកឧត្តម សួន ង៉ាន់ឡេង

អនុប្រធាន



ឯកឧត្តម អ៊ុង ឆី

លេខាធិការ



ឯកឧត្តម ឆាត់ ឈឿម

សមាជិក



ឯកឧត្តម យឹម ឃុនឃឿន

សមាជិក

សមាសភាពលេខាធិការដ្ឋានអមគណៈកម្មការទី៧



លោក **អុល ឆិមឈ**

ប្រធានស្តីទី

០៩៦ ៨២៥ ៧៧៨៨

៨-តួនាទី ភារកិច្ច និង សមត្ថកិច្ចគណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

ប្រការ១ :

គណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារីហៅកាត់ថា «គណៈកម្មការទី៨» និងសរសេរជាអក្សរកាត់ « គ.ស.ស.អ.យ. ក.ប.ក »។

ប្រការ២ :

គណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី មានតួនាទីជាសេនាធិការក្នុងការបំពេញមុខងារតំណាងមុខងារនីតិកម្ម និងមុខងារត្រួតពិនិត្យ និងធានាប្រមូលព័ត៌មាន ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា។

ប្រការ ៣ :

គណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី មានភារកិច្ចដូចតទៅ ៖

- ផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ ស្នើសុំធ្វើវិសោធនកម្មច្បាប់ និងទទួលពិនិត្យឲ្យយោបល់លើសេចក្តីស្នើច្បាប់ សេចក្តីព្រាងច្បាប់ និងបញ្ហាទាំងពួងដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- ទំនាក់ទំនងជាមួយគណៈកម្មការនានារបស់រដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីឈ្វេងយល់ជាមុននូវរាល់គំនិតផ្តួចផ្តើម និងការសម្រេចលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- អញ្ជើញតំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នកស្នើច្បាប់ដែលជាម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងមកបំភ្លឺចំពោះមុខគណៈកម្មការ
- អញ្ជើញតំណាងក្រសួងពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាង សង្គមស៊ីវិលចូលរួមឲ្យយោបល់អំពីបញ្ហាទាំងពួង
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការពិនិត្យ និងផ្តល់យោបល់លើសេចក្តីស្នើច្បាប់ សេចក្តីព្រាងច្បាប់ ឬបញ្ហាទាំងពួង ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ សំណូមពរ ឬចំណាប់ អារម្មណ៍ផ្សេងៗ ប្រសិនបើមាន

- ផ្តួចផ្តើមគំនិតរៀបចំសវនាការ កិច្ចពិគ្រោះយោបល់ និងសិក្ខាសាលាលើសេចក្តីស្នើច្បាប់ សេចក្តីព្រាងច្បាប់ ឬបញ្ហាទាំងពួង ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- សិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ តាមរយៈសារព័ត៌មានជាតិ និងអន្តរជាតិ របាយការណ៍របស់ក្រសួងជំនាញពាក់ព័ន្ធ បន្ទាប់មកធ្វើរបាយការណ៍តាមវិស័យ ដោយធ្វើការវិភាគ និងវាយតម្លៃហើយរាយការណ៍អំពីលទ្ធផលទាំងនោះ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ ឬសំណូមពរប្រសិនបើមាន
- ចុះបំពេញបេសកកម្មស្វែងរកព័ត៌មាន តាមក្រសួង ស្ថាប័ន និងតាមដាន ត្រួតពិនិត្យការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងភូមិភាគទាំង៨ បន្ទាប់មកធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអន្តរាគមន៍ទៅក្រសួងពាក់ព័ន្ធ ដើម្បីធ្វើការដោះស្រាយ
- ទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ និងស្ថានទូតនានា ដើម្បីឈ្វេងយល់អំពីបញ្ហាទាំងពួង ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ និងព្រឹទ្ធសភា
- ពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយដៃគូអភិវឌ្ឍនានា សភាបណ្តាប្រទេសក្នុងតំបន់ និងសកលលោក តាមរយៈទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក ក្នុងការឈ្វេងយល់អំពីការអភិវឌ្ឍការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ជាពិសេសកៀរគរជំនួយឧបត្ថម្ភផ្សេងៗសម្រាប់អភិវឌ្ឍធនធានមនុស្ស និងព្រឹទ្ធសភា
- បំពេញកាងារផ្សេងទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រគល់ជូន។

ប្រការ ៨ :

គណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី មានសមត្ថកិច្ចប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទដ្ឋានគតិយុត្តនានាជាធរមាន និងសេចក្តីសម្រេចនេះ។

ប្រការ ៩ :

គណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី គណៈកម្មការនានារបស់ព្រឹទ្ធសភាដែលមានការពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

(យោង៖ សេចក្តីសម្រេចលេខ: ០២៧/០៩១២/ពស/ស.រ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីតួនាទីភារកិច្ច និងសមត្ថកិច្ច និងលេខ:០៩៦/០៩១៤/ពស/ស.រ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពគណៈកម្មការទី៨ ព្រឹទ្ធសភា ដែលត្រូវបានកែសម្រួលឡើងវិញ)

សមាសភាពគណៈកម្មការទី៨ ព្រឹទ្ធសភា



លោកជំទាវ មាន សំអាន

ប្រធាន



លោកជំទាវ ពុំ ស៊ីថាន់

អនុប្រធាន



ឯកឧត្តម អាំ សំអាត

លេខាធិការ



ឯកឧត្តម ឆួន សាមិន

សមាជិក



លោកជំទាវ លី ឆារី

សមាជិកា

សមាសភាពលេខាធិការដ្ឋានអមគណៈកម្មការទី៨



លោក **ជាវណ្ណ រដ្ឋចេស្តា**

ប្រធាន

០១៦ ៦៧៨ ៩១០



លោក **ឆួន សុគន្ធារិទ្ធ**

អនុប្រធាន

០១២ ៦៤៤ ៩៩៦

៩-តួនាទី តារកិច្ច និងសមត្ថកិច្ចគណៈកម្មការ សាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ប្រការ ១ :

គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហៅកាត់ថា «គណៈកម្មការទី៩»និងសរសេរជាអក្សរកាត់ «គ៩ » ។

ប្រការ ២ :

គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានតួនាទីជាសេនាធិការឲ្យគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា ក្នុងការពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងបញ្ហាទាំងពួង ព្រមទាំងតាមដានការអនុវត្តការងារ កម្មវិធីនយោបាយ គោលនយោបាយជាតិរបស់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន។

ប្រការ ៣ :

គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចដូចតទៅ ៖

- ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងបញ្ហាទាំងពួងដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ជូន
- ទំនាក់ទំនងជាមួយគណៈកម្មការនានារបស់រដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីឈ្វេងយល់ជាមុននូវគំនិតផ្តួចផ្តើម និងការសម្រេចលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- អញ្ជើញតំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នកស្នើច្បាប់ ដែលជាម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងមកបំភ្លឺ ចំពោះមុខគណៈកម្មការ
- អញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាងសង្គមស៊ីវិលចូលរួមឲ្យយោបល់លើបញ្ហាផ្សេងៗ

- ធ្វើសេចក្តីរាយការណ៍ អំពីលទ្ធផលនៃការពិនិត្យ និងផ្តល់យោបល់លើ សេចក្តីព្រាង-ច្បាប់ សេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ សំណូមពរ ឬចំណាប់អារម្មណ៍ផ្សេងៗ ប្រសិនបើមាន
- សិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ តាមរយៈរបាយការណ៍របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ សារព័ត៌មានជាតិ អន្តរជាតិ និងសង្គមស៊ីវិល
- ធ្វើរបាយការណ៍ព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយធ្វើការវិភាគ និងវាយតម្លៃ បន្ទាប់មករាយការណ៍អំពីលទ្ធផលទាំងនោះជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា
- ចុះបំពេញបេសកកម្មស្វែងរកព័ត៌មានតាមក្រសួង ស្ថាប័ន និងតាមដាន ត្រួតពិនិត្យការផ្តល់សេវាសាធារណៈ ក្នុងការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការនៅមូលដ្ឋាន និងភូមិ-ភាគ ព្រមទាំងធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា និង/ឬលើកអនុសាសន៍ ឬធ្វើអន្តរាគមន៍ទៅ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការដោះស្រាយ ឬកែសម្រួល
- ទំនាក់ទំនងជាមួយអង្គការជាតិ-អន្តរជាតិ និងស្ថានទូតអន្តរជាតិនានា ដើម្បីឈ្វេងយល់នូវបញ្ហាទាំងពួង ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈ-កម្មការ
- ពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការផ្តួចផ្តើមគំនិតរៀបចំកិច្ចពិគ្រោះយោបល់ សិក្ខាសាលា វេទិកា សាធារណៈ បេសកកម្មក្នុង និងក្រៅប្រទេសរបស់គណៈកម្មការ
- បំពេញការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រគល់ជូន។

ប្រការ ៨ :

គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងសេចក្តីសម្រេចនេះ ។

ប្រការ ៨ :

គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មការនានារបស់ព្រឹទ្ធសភា ដែលមានការពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

(ឃោង៖ សេចក្តីសម្រេចលេខ: ០២៨/០៩១២/ពស/ស.រ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីតួនាទីការកិច្ច និងសមត្ថកិច្ច និងលេខ:០៩៧/០៩១៤/ពស/ស.រ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពគណៈកម្មការទី៩ ព្រឹទ្ធសភា ដែលត្រូវបានកែសម្រួលឡើងវិញ)

សមាសភាពគណៈកម្មការទី៩ ព្រឹទ្ធសភា



ឯកឧត្តម គង់ សារាជ

ប្រធាន



ឯកឧត្តម សួន លន់

អនុប្រធាន



ឯកឧត្តម ពុធ ឌុច

លេខាធិការ



ឯកឧត្តម ទឹម ផន

សមាជិក



ឯកឧត្តម ង៉ាន់ ភុច

សមាជិក

សមាសភាពលេខាធិការដ្ឋានអមគណៈកម្មការទី៩



លោក **ចំរើន ថាភុច**

ប្រធាន

០១៦ ៨៣០ ៩៩០

១០-តួនាទី ភារកិច្ច និងសមត្ថកិច្ចគណៈកម្មការ អង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ

ប្រការ ១ :

គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ ហៅកាត់ថា " គណៈកម្មការទី១០ " សរសេរជាអក្សរកាត់ " គ.អ.ប.ប្រ.ព " ។

ប្រការ ២ :

គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ មានតួនាទីជាសេនាធិការព្រឹទ្ធសភាក្នុងការបំពេញមុខងារនីតិកម្ម មុខងារត្រួតពិនិត្យ និងមុខងារតំណាង និងធានាដល់ការប្រមូលព័ត៌មានដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

ប្រការ ៣ :

គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ មានភារកិច្ចដូចតទៅ ៖

- ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ជូន
- ផ្តួចផ្តើមគំនិតស្នើច្បាប់ ឬវិសោធនកម្មច្បាប់ ឬបញ្ហាទាំងពួង ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- ពិនិត្យ តាមដានការអនុវត្តច្បាប់របស់អជ្ញាធរដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងភូមិភាគទាំង៨ បន្ទាប់មកធ្វើរបាយការណ៍ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ផ្តល់អនុសាសន៍ ឬសម្រេច និង ឬលើកជាអនុសាសន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការដោះស្រាយ
- ទំនាក់ទំនងជាមួយគណៈកម្មការនានារបស់រដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីសិក្សាឈ្វេងយល់ជាមុននូវគំនិតផ្តួចផ្តើម និងការសម្រេចលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលពាក់ព័ន្ធនឹងវិស័យជាសម្តកិច្ចរបស់គណៈកម្មការ
- អញ្ជើញតំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នកស្នើច្បាប់ ដែលជាម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង មកបំភ្លឺចំពោះមុខគណៈកម្មការ
- អញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាងសង្គមស៊ីវិលចូលរួមឲ្យយោបល់លើបញ្ហាផ្សេងៗ
- សិក្សាស្រាវជ្រាវ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការពិនិត្យ សិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយភ្ជាប់ជាមួយនូវអនុសាសន៍ ឬសំណូមពរ ឬចំណាប់អារម្មណ៍ផ្សេងៗ ប្រសិនបើមាន

- ធ្វើរបាយការណ៍អំពីព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសម្ថកិច្ចរបស់គណៈកម្មការ ដោយធ្វើការវិភាគ និងវាយតម្លៃ បន្ទាប់មករៀបចំជារបាយការណ៍ពិស្តារ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា
- ផ្តួចផ្តើមគំនិតរៀបចំកិច្ចពិគ្រោះយោបល់ អំពីវេទិកាសាធារណៈ សិក្ខាសាលា កម្មវិធីបេសកកម្មក្នុង និងក្រៅប្រទេសរបស់គណៈកម្មការ បន្ទាប់មកធ្វើរបាយការណ៍លទ្ធផលជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គព្រឹទ្ធសភា
- ពង្រឹង ពង្រីក និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ សភាបណ្តាប្រទេសក្នុងតំបន់ និងសកលលោក ស្ថានទូតអន្តរជាតិនានា និងអង្គការជាតិ អន្តរជាតិនានា តាមរយៈទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងសិក្សាឈ្វេងយល់បន្ថែម ពីការវិវត្តការងារពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- ធានាផ្តល់របាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ។

ប្រការ ៨ :

គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ មានសមត្ថកិច្ចប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទដ្ឋានគតិយុត្តជាធរមាន និងសេចក្តីសម្រេចនេះ ។

ប្រការ ៩ :

គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ គណៈកម្មការនានារបស់ព្រឹទ្ធសភាដែលមានការពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលបន្ទុក អនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

(យោង៖ សេចក្តីសម្រេចលេខ: ១១៦/០៩១៤/ពស/ស.រ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៤ ស្តីពីតួនាទីភារកិច្ច និងសមត្ថកិច្ច និងលេខ:០៩៨/០៩១៤/ពស/ស.រ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពគណៈកម្មការទី១០ ព្រឹទ្ធសភា)

សមាសភាពគណៈកម្មការទី១០ ព្រឹទ្ធសភា



ឯកឧត្តម ហុង សុខហួរ

ប្រធាន



ឯកឧត្តម ម៉ម ប៊ុនធាង

អនុប្រធាន



ឯកឧត្តម សេង ម៉ារឌី

លេខាធិការ



ឯកឧត្តម ម៉ែន ស៊ីថាន់

សមាជិក



ឯកឧត្តម សោ ចាន់ដេត

សមាជិក

សមាសភាពលេខាធិការដ្ឋានអមគណៈកម្មការទី១០



លោក **ម៉ែង ចារ័ត្ន**

អនុប្រធាន

០១២ ២៥ ៧៧ ៧៥



លោក **លី សាវុធ**

ប្រធាន

០១២ ៦១ ៦៥ ៦០



លោកស្រី **ហ៊ាន ម៉ាក់**

អនុប្រធាន

០៧៧ ៦២២ ៩៩១

១៨- សមាសភាព តួនាទី ភារកិច្ច និងសមត្ថកិច្ចក្រុមសហជីពព្រឹទ្ធសភា នីតិកាលទី៣

ក្រុមទី១ ៖

ល.រ	គោត្តនាម-នាម	តួនាទី
១	ឯកឧត្តម **ជា ដេដ្ឋ**	ប្រធាន
២	ឯកឧត្តម **យ៉ង់ សេម**	អនុប្រធាន
៣	ឯកឧត្តម **ម៉ាន់ ឈឿន**	សមាជិក
៤	លោកជំទាវ **ឡាក់ អូន**	សមាជិកា
៥	ឯកឧត្តម **ឈួន សឿន**	សមាជិក
៦	ឯកឧត្តម **ជុំ ឥច**	សមាជិក
៧	ឯកឧត្តម **អ៊ុក គង់**	សមាជិក
៨	ឯកឧត្តម **ស៊ឹម កា**	សមាជិក
៩	លោកជំទាវ **កែវ ម៉ាលី**	សមាជិកា
១០	ឯកឧត្តម **ខាន់ ម៉ាត់**	សមាជិក

ក្រុមទី២ ៖

ល.រ	គោត្តនាម-នាម	តួនាទី
១	ឯកឧត្តម **ង៉ូ ឥច**	ប្រធាន
២	ឯកឧត្តម **ម៉ុង ឫទ្ធី**	អនុប្រធាន
៣	ឯកឧត្តម **ឡាយ អ៊ីពិសិទ្ធិ**	សមាជិក
៤	ឯកឧត្តម **ម៉ែន ស៊ីផាន់**	សមាជិក
៥	ឯកឧត្តម **អន ស៊ុំ**	សមាជិក
៦	ឯកឧត្តម **ចាន់ ណារ៉េត**	សមាជិក
៧	ឯកឧត្តម **សើយ កែវ**	សមាជិក
៨	ឯកឧត្តម **ឃឹម សេត**	សមាជិក
៩	ឯកឧត្តម **អ៊ុំ ម៉ាឡូរីន**	សមាជិក
១០	ឯកឧត្តម **អៀវ បណ្ណាការ**	សមាជិក

ក្រុមទី៣ ៖

ល.រ	គោត្តនាម-នាម	តួនាទី
១	ឯកឧត្តម **អ៊ុក ប៊ុនឈឿន**	ប្រធាន
២	លោកជំទាវ **ទី ម៉ូរ៉ាស៊ី**	អនុប្រធាន
៣	ឯកឧត្តម **ជា សុន**	សមាជិក
៤	ឯកឧត្តម **ឈិត គឹមយាត**	សមាជិក
៥	ឯកឧត្តម **ថុច ចន់**	សមាជិក
៦	លោកជំទាវ **ឈុក ឈីម**	សមាជិកា
៧	ឯកឧត្តម **លី យ៉ុងផាត់**	សមាជិក
៨	ឯកឧត្តម **ហុច ទូហាយ**	សមាជិក
៩	ឯកឧត្តម **ហេង ម៉ូរ៉ា**	សមាជិក
១០	ឯកឧត្តម **ឡាវ ម៉េងឃីន**	សមាជិក

ក្រុមទី៤ ៖

ល.រ	គោត្តនាម-នាម	តួនាទី
១	ឯកឧត្តម **នៃ ម៉ៃណា**	ប្រធាន
២	លោកជំទាវ **ហាន សំអាន**	អនុប្រធាន
៣	សម្តេចវិបុលសេនាភក្តី **សាយ ឈុំ**	សមាជិក
៤	ឯកឧត្តម **ង៉ាន់ ភុច**	សមាជិក
៥	លោកជំទាវ **ពុំ ស៊ីថាន់**	សមាជិកា
៦	ឯកឧត្តម **អ៊ុច ទី**	សមាជិក
៧	ឯកឧត្តម **អាំ សំអាត**	សមាជិក
៨	ឯកឧត្តម **ឆាត់ ឈឿម**	សមាជិក
៩	ឯកឧត្តម **ឆួន សាមិន**	សមាជិក
១០	ឯកឧត្តម **ឈួន ឡេច**	សមាជិក

ក្រុមទី៥ ៖

ល.រ	គោត្តនាម-នាម	តួនាទី
១	ឯកឧត្តម **គង់ សារាជ**	ប្រធាន
២	ឯកឧត្តម **សួន លន់**	អនុប្រធាន
៣	ឯកឧត្តម **ទេព ចន**	សមាជិក
៤	ឯកឧត្តម **ពុធ ឌូវ**	សមាជិក
៥	ឯកឧត្តម **ទឹម ផន**	សមាជិក
៦	ឯកឧត្តម **ម៉ម ប៊ុនធាង**	សមាជិក
៧	លោកជំទាវ **ជិន សុខីម**	សមាជិកា
៨	ឯកឧត្តម **កុក អាន**	សមាជិក
៩	ឯកឧត្តម **ខៀវ មុត**	សមាជិក
១០	ឯកឧត្តម **ប្រាក់ ចំរើន**	សមាជិក

ក្រុមទី៦ ៖

ល.រ	គោត្តនាម-នាម	តួនាទី
១	ឯកឧត្តម **ឆាវ វណ្ណុល**	ប្រធាន
២	ឯកឧត្តម **ហុង សុខហួរ**	អនុប្រធាន
៣	ឯកឧត្តម **ឃឹម ឃុនឃឿន**	សមាជិក
៤	លោកជំទាវ **លី នារី**	សមាជិកា
៥	លោកជំទាវ **ឡាយ ម៉ូនី**	សមាជិកា
៦	ឯកឧត្តម **ចេម គីមអ៊ាង**	សមាជិក
៧	ឯកឧត្តម **សោ ចាន់ដេត**	សមាជិក
៨	ឯកឧត្តម **សេង ម៉ារី**	សមាជិក
៩	លោកជំទាវ **ថាក់ ឡានី**	សមាជិកា
១០	ឯកឧត្តម **ឃូ ស៊ាងហោង**	សមាជិក
១១	ឯកឧត្តម **សួន ង៉ាន់ឡេង**	សមាជិក

(យោង៖ សេចក្តីសម្រេចលេខ: ៤៥១/០៧១៦/អពស/នវ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦
ស្តីពីការចាត់តាំងក្រុមសមាជិកព្រឹទ្ធសភា សម្រាប់នីតិកាលទី៣ ដែលត្រូវបានកែសម្រួល)

តួនាទី តារកិច្ច និងសមត្ថកិច្ចរបស់ក្រុមសមាជិកព្រឹទ្ធសភា

ប្រការ ១ : សេចក្តីសម្រេចនេះ មានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមសមាជិកព្រឹទ្ធសភា ឲ្យដំណើរការដោយរលូន មានប្រសិទ្ធភាព និង គុណភាពពិតប្រាកដ។

ប្រការ ២ : ក្រុមសមាជិកព្រឹទ្ធសភា គឺជាការប្រមូលផ្តុំសមាជិកព្រឹទ្ធសភាយ៉ាងតិច១០រូប ដែលមាននិន្នាការនយោបាយដូចគ្នា ឬទស្សនៈនយោបាយស្របគ្នា ។

ដំណើរការបង្កើតក្រុម ត្រូវប្រតិបត្តិតាមប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

ប្រការ ៣ : ក្រុមសមាជិកព្រឹទ្ធសភាបំពេញតួនាទី ដើម្បីប្រមូលផ្តុំបញ្ញាញាណនយោបាយរបស់ព្រឹទ្ធសភា សំដៅបម្រើឲ្យការបញ្ចេញយោបល់របស់តំណាងក្រុម នៅក្នុងសម័យប្រជុំព្រឹទ្ធសភានីមួយៗ ឲ្យធានាបានតាមរបៀបវារៈ និងពេលវេលាកំណត់ ព្រមទាំងធានាថា ពហុមតិ និងពហុនិយមខាងនយោបាយ ត្រូវបានអនុវត្តដោយថ្លៃថ្នូរ មានគុណធម៌ និង សុជីវធម៌ ក្នុងក្របខ័ណ្ឌនៃក្រមសីលធម៌សមាជិកព្រឹទ្ធសភា គ្មានការរំលោភបំពាន និងគ្មានការធើសអើង ហើយសកម្មភាពនីតិកៈទូទៅរបស់សមាជិកព្រឹទ្ធសភា ដែលតំណាងឲ្យភូមិភាគ និងប្រជាជាតិខ្មែរទាំងមូល។

ប្រការ ៤ : **ក្រុមសមាជិកព្រឹទ្ធសភា មានភារកិច្ចដូចតទៅៈ**

- រួមគ្នាពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដើម្បីរៀបចំតំណាងក្រុមថ្លែងយោបល់ក្នុងនាមក្រុម នៅក្នុងសម័យប្រជុំព្រឹទ្ធសភា និងប្រកាន់ជំហររួមរបស់ក្រុម ក្នុងការអនុម័ត។

- រួមគ្នាផ្តួចផ្តើមគំនិតស្នើច្បាប់ ឬស្នើវិសោធនកម្មច្បាប់

- រួមគ្នាប្រជុំ ដើម្បីចែករំលែកព័ត៌មាន ពិគ្រោះគ្នាកំណត់គោលជំហររបស់ក្រុមទៅលើបញ្ហាបច្ចុប្បន្នភាពណាមួយ ដែលក្រុមយកចិត្តទុកដាក់ ឬសម្រាប់ការថ្លែង ឬប្រកាសជំហរ ជាសាធារណៈ ។

ប្រធាន និងអនុប្រធានក្រុមទទួលខុសត្រូវដឹកនាំ និងចាត់ចែងក្រុម ហើយត្រូវមានរបាយការណ៍ទៀងទាត់ប្រចាំខែជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។

ក្រុមសមាជិកព្រឹទ្ធសភាអាចស្នើសុំនូវសេវាគាំទ្រចាំបាច់មួយចំនួន ពីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមសេចក្តីអនុញ្ញាតពីប្រធានព្រឹទ្ធសភា ។

ប្រការ ៥ : ក្រុមសមាជិកព្រឹទ្ធសភា ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ក្រមសីលធម៌សមាជិកព្រឹទ្ធសភា លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីសម្រេចនានារបស់ព្រឹទ្ធសភា ។

ប្រការ ៦ : ប្រធាន អនុប្រធាន និងសមាជិក សមាជិកាព្រឹទ្ធសភាក្នុងក្រុមនីមួយៗ និង អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

(<u>ឃោង</u>៖ សេចក្តីសម្រេចលេខ: ០៤៦/១២១២/ពស/សរ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២)

១៩- សមាសភាព តួនាទី ភារកិច្ច និងសមត្ថកិច្ចក្រុមការងារអន្តរជាតព្រឹទ្ធសភា និងក្រុមមិត្តភាពជាមួយសភាប្រទេសនានា

ក. ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចការអន្តរសភាអាស៊ាន (AIPA)

ប្រការ ១ : ចាត់តាំងក្រុមសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកកិច្ចការអន្តរសភាអាស៊ាន (AIPA) ដែលត្រូវបានកែសម្រួល និងមានសមាសភាពដូចតទៅ :

១- ឯកឧត្តម	ខេង	ធន	ប្រធាន
២- ឯកឧត្តម	ឈិត	គឹមយាត	អនុប្រធាន
៣- ឯកឧត្តម	ចាន់	ណារ៉េត	អនុប្រធាន
៤- ឯកឧត្តម	ម៉ែន	ស៊ីផាន់	សមាជិក
៥- ឯកឧត្តម	ង៉ាន់	ឆុង	សមាជិក

- គណៈកម្មាធិការប្រតិបត្តិ

១- ឯកឧត្តម	ឈិត	គឹមយាត
២- ឯកឧត្តម	ខៀវ	មុត
៣- ឯកឧត្តម	ប្រាក់	ចំរើន

- គណៈកម្មាធិការនយោបាយ

១- ឯកឧត្តម	យ៉ិត	សែម
២- ឯកឧត្តម	អាំ	សំអាត
៣- ឯកឧត្តម	ម៉ម	ប៊ុនធាង

- គណៈកម្មាធិការសេដ្ឋកិច្ច

១- ឯកឧត្តម	ម៉ុង	ឫទ្ធី
២- ឯកឧត្តម	ឈួន	ឡេង
៣- លោកជំទាវ	កែវ	ម៉ាលី
៤- ឯកឧត្តម	ឃួ	សាចហោង

- គណៈកម្មាធិការសង្គមកិច្ច

១- ឯកឧត្តម	គង់	សារាជ
២- ឯកឧត្តម	ងាវ	ឥណ្ណល
៣- ឯកឧត្តម	អ៊ុង	ធី
៤- ឯកឧត្តម	ឃឹម	ឃុនឃឿន

- គណៈកម្មាធិការរៀបចំ និង ចាត់ចែងការងារ

១- ឯកឧត្តម	ម៉ែន	ស៊ីផាន់
២- ឯកឧត្តម	សួន	លន់
៣- ឯកឧត្តម	សោ	ចាន់ដេត

- **គណៈកម្មាធិការសមាជិកសភាស្ត្រី**

១- លោកជំទាវ	**ម៉ាន**	**សំអាន**	
២- លោកជំទាវ	**ពុំ**	**ស៊ីចាន់**	
៣- លោកជំទាវ	**ឡាក់**	**អូន**	
៤- លោកជំទាវ	**ឈុក**	**ឈឹម**	
៥- លោកជំទាវ	**ថាក់**	**ឡានី**	
៦- លោកជំទាវ	**ជិន**	**សុខីម**	

- **ទីប្រឹក្សា**

១- លោកជំទាវ	**ឌី**	**ប៉ូរ៉ាស៊ី**
២- ឯកឧត្តម	**អ៊ុំ**	**សារីឆ**

- **មន្ត្រីឯកទេស**

១- ឯកឧត្តម	**ឈឹម**	**សុទ្ធគុណ**
២- ឯកឧត្តម	**សោម**	**សាវុធ**

- **មន្ត្រីជំនួយការ**

១- លោក	**កុយ**	**ម៉ាឡៃវីរៈ**	ជំនួយការ
២- លោក	**សាន**	**សុខុម**	ជំនួយការ
៣- លោក	**សំអឿន**	**ម៉ារឌី**	ជំនួយការ
៤- លោកស្រី	**ឡា**	**ណារីតា**	ជំនួយការ
៥- កញ្ញា	**សាន**	**ចាន់ប្រស្ញា**	ជំនួយការ

ប្រការ ២ : ក្រុមសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកកិច្ចការអន្តរសភាអាស៊ាន (AIPA) ត្រូវប្រតិបត្តិការងារទៅតាម **តួនាទី ភារកិច្ច** ដូចតទៅ ៖

១. ខិតខំលើកកម្ពស់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការ ជាមួយសភាបណ្តាប្រទេស ទាំងក្នុងតំបន់ និងលើសកលលោក ។ បង្កើត ផ្លាស់ប្តូរ ចែករំលែកព័ត៌មាន សម្របសម្រួល និងពិគ្រោះយោបល់ សំដៅជំរុញឲ្យមានការខិតជិតគ្នារវាងសភាទាំងពីរ ។ សិក្សា ស្រាវជ្រាវ ស្វែងរកដំណោះស្រាយលើបញ្ហាទាំងឡាយ ផ្សព្វផ្សាយគោលការណ៍ **សន្តិភាព សន្តិសុខ និងវិបុលភាព** ដើម្បីផលប្រយោជន៍រួម ក៏ដូចជាផលប្រយោជន៍របស់ប្រទេសជាតិ ។

